ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៥២ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបើកដំណើរការឡើងវិញ
# គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន

ចាប់តាំងដើមសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ២០២១ ដោយមានកិច្ចសហការ និងគាំទ្រពីសំណាក់រដ្ឋបាលរាជធានី-ខេត្ត មន្ត្រីសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសសាធារណៈ និងឯកជន នៅភូមិសាស្ត្រដែលមានហានិភ័យទាបបានចាប់ផ្តើមដំណើរការបង្រៀន និងរៀនតាមបណ្តុំ បន្ទាប់ពីការផ្អាកដំណើរការចាប់តាំងពីការផ្ទុះឡើងនៃព្រឹត្តិការណ៍ឆ្លងសហគមន៍ ២០កុម្ភៈ។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវសេចក្តីណែនាំចំនួន២ ៖ ១). សេចក្តណែនាំលេខ ៤៦ អយក.សណន ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្រៀន និងរៀនតាមបណ្តុំសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន នៅភូមិសាស្ត្រដែលមានហានិភ័យទាប និង២).សេចក្តីណែនាំលេខ៥០អយក. សណន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ការលើកកម្ពស់សុខភាព និងសុវត្ថិភាពសិក្សាក្នុងការបង្រៀននិងរៀនតាមបណ្តុំ សម្រាប់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន។

គំនិតផ្តួចផ្តើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីធ្វើឱ្យមានប្រក្រតីភាពវិស័យអប់រំឡើងវិញ បាននិងកំពុងដំណើរការប្រកបដោយជោគជ័យ និងប្រុងប្រយ័ត្ន។ គ្រឹះស្ថានអប់រំចំណេះទូទៅសាធារណៈ និងឯកជនបាននិងកំពុងដំណើរការតាមគ្រប់រូបភាព ដូចជា ការបើកសាលារៀនឡើងវិញនៅកម្រិតអប់រំចំណេះទូទៅ, ការបង្រៀននិងរៀនជាបណ្តុំ, ការបង្រៀននិងរៀនសម្រាប់ថ្នាក់ទី៩ និងទី១២ និងការបន្តរៀនតាមអនឡាញនៅតាមរាជធានី ខេត្ត។

ឈរលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់គោលការណ៍ ១១ចំណុច សម្រាប់ការបើកដំណើរឡើងវិញក្នុងដំណាក់កាលទី១ សម្រាប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ដូចខាងក្រោម៖

## ទី១. ការបើកដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ នៅគ្រឹះស្ថានឧត្តមសិក្សា ត្រូវចាប់ផ្តើមពីកម្រិតសាកល្បង

- អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ (ទីតាំង ចំនួននិស្សិត ប្រភេទជំនាញ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម) ក្រសួងអប់រំ យុវជន និងកីឡាអនុញ្ញាតឱ្យចាប់ផ្តើមបើក

ដំណើរការបង្រៀន និងរៀន (នៅក្នុងថ្នាក់រៀន) ការអនុវត្តប្រតិបត្តិ (នៅក្នុងមន្ទីរពិសោធន៍ ឬសាលសហសិក្សា) និងការស្រាវជ្រាវ (នៅក្នុងស្ថានីយ៍ មន្ទីរ ពិសោធន៍ ឬនៅលើទីវាល) ជាកម្រិតសាកល្បង ទ្រង់ទ្រាយតូច ដែលអាចគ្រប់គ្រងបាន និងសម្រាប់ការដកស្រង់បទពិសោធន៍ និងឧត្តមានុវត្តន៍

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើត "**យន្តការកាត់បន្ថយហានិភ័យ**" ដោយមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ (គណៈគ្រប់គ្រង បុគ្គលិកអប់រំ និស្សិត ...) អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃគ្រឹះស្ថាននីមួយៗ និងការសិក្សាជាលក្ខណៈវិទ្យាសាស្ត្រ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើត "**យន្តការផ្តល់ព័ត៌មាន និងពិគ្រោះយោបល់**" ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាលើស្ថានភាពដែលកើតមានឡើង នៅក្នុងដំណាក់កាលនីមួយៗនៃការបើកដំណើរការ និងស្វែងរកដំណោះស្រាយរួមគ្នា។

**ទី២. ការបើកដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ នៅគ្រឹះស្ថានឧត្តមសិក្សាត្រូវគោរពតាមបទដ្ឋានសុខាភិបាលជាចាំបាច់**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនបំផុតតាមសេចក្តីណែនាំលេខ៥០ ស្តីពីគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ការលើកកម្ពស់សុខភាព និងសុវត្ថិភាពសិក្សាក្នុងការបង្រៀននិងរៀនតាមបណ្តុំ សម្រាប់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ក៏ដូចជាសេចក្តីណែនាំ និងវិធានការសុខាភិបាលផ្សេងទៀត
- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានមធ្យោបាយជាក់លាក់ សម្រាប់បម្រើដល់ការឆ្លើយតប ក្នុងករណីសង្ស័យថាមានរោគសញ្ញាជំងឺកូវីដ-១៩ នៅលើបុគ្គលណាម្នាក់ ដែលមានវត្តមានក្នុងបរិវេណគ្រឹះស្ថានសិក្សា, យន្តការទំនាក់ទំនងជាមួយភ្នាក់ងារសុខាភិបាល, និងយន្តការអន្តរាគមន៍ផ្នែកសុខាភិបាល ដើម្បីត្រួតពិនិត្យស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩។

**ទី៣. ការបន្តអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ សម្រាប់និស្សិតដែលរៀនក្នុងថ្នាក់ដោយផ្ទាល់ និងរៀនតាមប្រព័ន្ធអនឡាញ និងត្រូវធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត និងសមធម៌**

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវធានាថាគ្រប់និស្សិតទាំងអស់នឹងទទួលបានឱកាសពីដំណើរការបង្រៀននិងរៀនសាកល្បងនេះ ដោយការស្ម័គ្រចិត្ត (និស្សិតដែលមិនស្ម័គ្រចិត្តមករៀននៅទីតាំងផ្ទាល់ត្រូវទទួលបានការបង្រៀនតាមប្រព័ន្ធអនឡាញ) និងដោយសមធម៌ (និស្សិតដែលមករៀននៅទីតាំងផ្ទាល់ ត្រូវរៀនតាមការបែងចែក)
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវទទួលខុសត្រូវនូវរាល់បាតុភាព ដែលកើតឡើងដោយការរៀបចំដំណើរការសាកល្បងបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវនេះ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវទទួលខុសត្រូវដោយខ្លួនឯង នូវការវិនិយោគបន្ថែមលើការបំពាក់សម្ភារបរិក្ខារចាំបាច់សម្រាប់អនុវត្តវិធានការសុខាភិបាល ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបង្រៀនតាមអនឡាញ ។

**ទី៤. គណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា វាយតម្លៃកម្រិតហានិភ័យនៃការផ្ទុះឡើង និងការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ នៅក្នុងបរិវេណនៃគ្រឹះស្ថានឧត្តមសិក្សា ដោយមានការចូលរួម**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវពិនិត្យតាមដានសេចក្តីប្រកាសព័ត៌មាន សេចក្តីជូនដំណឹង ឬសេចក្តីណែនាំផ្សេងៗរបស់រដ្ឋបាលរាជធានី-ខេត្ត ឬអាចស្នើសុំយោបល់ទៅកាន់គណៈអភិបាលរាជធានី-ខេត្ត ដើម្បីបញ្ជាក់ពីកម្រិតហានិភ័យនៃភូមិសាស្ត្រ ដែលខ្លួនស្ថិតនៅ
- តាមរយៈ «យន្តការកាត់បន្ថយហានិភ័យ» ដែលគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវបង្កើតឡើង គ្រឹះស្ថានឧត្តមសិក្សាត្រូវធ្វើការសម្រេចចិត្តលើកម្រិតហានិភ័យ ដែលអាចកើតមានចំពោះបុគ្គលិកអប់រំ និស្សិត ជាលក្ខណៈបុគ្គល ឬជាលក្ខណៈស្ថាប័ន ហើយផ្តល់ព័ត៌មាន និងលើកឡើងជាដំណោះស្រាយបន្ទាន់ ដើម្បីពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា។

**ទី៥. ការផ្តល់សិទ្ធិក្នុងការសម្រេចចិត្ត និងការទទួលខុសត្រូវជាលក្ខណៈស្ថាប័ន ជូនដល់គណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ក្នុងការកំណត់កាលបរិច្ឆេទ និងលំដាប់លំដោយនៃការសាកល្បងដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ**

- គ្រឹះស្ថានឧត្តមសិក្សាអាចសម្រេចចិត្តក្នុងការបន្តដំណើរការបង្រៀននិងរៀន តាមប្រព័ន្ធអនឡាញទាំងស្រុងជាបន្តទៀត ឬសាកល្បងដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវនៅកាលបរិច្ឆេទកំណត់ណាមួយ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង
- គ្រឹះស្ថានសិក្សាឧត្តមសិក្សាអាចសម្រេចចិត្ត ក្នុងការសាកល្បងដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ សម្រាប់តែផ្នែកណាមួយនៃកម្មវិធីបណ្តុះបណ្តាល ឆ្នាំសិក្សា ឬក្រុមនិស្សិតជាក់លាក់ណាមួយ ។

**ទី៦. ការប្រមូលផ្តុំ និងការជួបជុំរវាងបុគ្គលិកអប់រំ និងនិស្សិត នៅក្នុងដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ មានចំនួនឱ្យលើស ២០នាក់ក្នុង១ថ្នាក់**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវសម្រេចចិត្ត និងទទួលខុសត្រូវប្រកបដោយសុភវិនិច្ឆ័យបំផុតទៅលើការអនុញ្ញាតឱ្យមានចំនួនមនុស្សប្រមូលផ្តុំ និងជួបជុំ ដែលធានាបាននូវគម្លាតសុវត្ថិភាពយ៉ាងតិច ១,៥ ម៉ែត្រ
- គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំសេចក្តីណែនាំដោយឡែក ដើម្បីបែងចែកកន្សោមអាទិភាពនៃមនុស្ស (បុគ្គលិកអប់រំ និងនិស្សិត) ដែលអាចមកចូលរួមក្នុងដំណើរការសាកល្បងនៃការបង្រៀន និងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ ៖

  ក. និស្សិតដែលពុំមានលទ្ធភាពរៀនតាមប្រព័ន្ធអនឡាញ ទាល់តែសោះ

  ខ. បុគ្គលិកអប់រំ និងនិស្សិត ដែលត្រូវសិក្សានៅក្នុងកម្មវិធីបណ្តុះបណ្តាល ឬមុខវិជ្ជាដែលតម្រូវឱ្យមានការអនុវត្តប្រតិបត្តិ

គ. បុគ្គលិកអប់រំ និងនិស្សិតដែលត្រូវបង្រៀននិងរៀន នៅឆ្នាំសិក្សាចុងក្រោយ ដែលត្រូវត្រៀមប្រឡងបញ្ចប់ការសិក្សា ឬដែលត្រូវសិក្សាមុខវិជ្ជាចាំបាច់ណាមួយ ដែលតម្រូវឱ្យមានការជួបមុខគ្នា

ឃ. បុគ្គលិកអប់រំ និងនិស្សិតដែលត្រូវចូលរួមនៅក្នុងដំណើរការស្រាវជ្រាវ ការចុះទីវាល ការពិសោធន៍វិទ្យាសាស្ត្រ ។ល។

ង. បុគ្គលិកអប់រំ និងនិស្សិតដែលត្រូវមកធ្វើស្វ័យសិក្សា ឬស្វែងរកឯកសារនៅបណ្ណាល័យជាលក្ខណៈវេលាកាល។

**ទី៧. ការបង្កើតគណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា**

- បង្កើត "**គណៈកម្មការសុខភាពសិក្សា**" និងដំណើរការ "**បន្ទប់សុខភាព**" ដូចក្នុងគំរូឧបសម្ព័ន្ធ
- គ្រឹះស្ថានឧត្តមសិក្សាត្រូវសម្អាត ថែទាំ និងលើកកម្ពស់អនាម័យសិក្សា នៅមុនពេលទទួលការអនុញ្ញាតឱ្យបើកដំណើរការសាកល្បង
- រាល់សកម្មភាពនៃការលក់ដូរចំណីអាហារ, អាហារដ្ឋាន សកម្មភាពកីឡា, ការប្រើប្រាស់ប្រភពទឹកទទួលទានរួមគ្នា ... មិនត្រូវអនុញ្ញាតឡើយ នៅក្នុងដំណាក់កាលសាកល្បង
- គ្រឹះស្ថានឧត្តមសិក្សាត្រូវហាមឃាត់ និងត្រូវចាត់វិធានការរដ្ឋបាលយ៉ាងម៉ឺងម៉ាត់ចំពោះការប្រាស្រ័យទាក់ទងគ្នាជាលក្ខណៈរូបសាស្ត្រ ឬទំនាក់ទំនងឆ្លងពីថ្នាក់រៀនមួយទៅថ្នាក់រៀនមួយទៀត
- បុគ្គលដែលមានវត្តមាននៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ត្រូវតែពាក់ម៉ាសជាប្រចាំ និងជាកាតព្វកិច្ច និងត្រូវពង្រឹងការអនុវត្តវិធានការណ៍ "**៣ការពារ ៣កុំ**" ឱ្យបានខ្ជាប់ខ្ជួន
- គ្រឹះស្ថានឧត្តមសិក្សាត្រូវស្នើសុំឱ្យប្រតិភូ ឬភ្ញៀវទាំងឡាយ ដែលមកត្រួតពិនិត្យដំណើរការរៀននិងបង្រៀន ឱ្យស្ថិតនៅខាងក្រៅបរិវេណថ្នាក់រៀន និងមិនអនុញ្ញាតឱ្យចូលមកក្នុងថ្នាក់រៀន ឬប៉ះពាល់ជាលក្ខណៈរូបសាស្ត្រជាមួយនិស្សិតជាដាច់ខាត។

**ទី៨. ការធ្វើតេស្តកូវីដ-១៩ សាស្ត្រាចារ្យ និងនិស្សិតគ្រប់រូប ប្រសិនបើមានលទ្ធភាព**

- មុនពេលចាប់ដំណើរការ និងក្នុងពេលសាកល្បងបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំផែនការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយចៃដន្យ និងជាប្រចាំសម្រាប់បុគ្គលិកអប់រំ និងនិស្សិត តាមលទ្ធភាពធនធានជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា
- ផ្តល់ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ឧបករណ៍តេស្តរហ័ស ដល់បុគ្គលិកទទួលបន្ទុកឱ្យមានចំណេះដឹងពិតប្រាកដក្នុងការធ្វើតេស្តរហ័ស ទាំងការយកសំណាក ការបកស្រាយលទ្ធផល និងការទុកដាក់កាកសំណល់ប្រកបដោយសុវត្ថិភាព។

## ទី៩. ការរៀន និងបង្រៀនក្នុងថ្នាក់សម្រាប់សាស្ត្រាចារ្យ និងនិស្សិតដែលបានចាក់វ៉ាក់សាំង និងដែលគ្មានរោគប្រចាំខ្លួន

- បុគ្គលិកអប់រំ ឬនិស្សិតដែលមានអាយុលើសពី៥០ឆ្នាំឡើងទៅ ឬដែលមានជំងឺប្រចាំកាយ គួរតែបន្តបង្រៀននិងរៀនតាមប្រព័ន្ធអនឡាញ
- ការចាប់ផ្តើមនៅដំណាក់កាលសាកល្បងនៃការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ ត្រូវផ្តល់ជូនជាអាទិភាពសម្រាប់បុគ្គលដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បាន ២ដូស ដែលមានបញ្ជាក់ដោយប័ណ្ណចាក់វ៉ាក់សាំង
- បុគ្គលិកអប់រំ និងនិស្សិតដែលធ្វើដំណើរមកពី ស្នាក់នៅ ឬឆ្លងកាត់តំបន់ដែលមានហានិភ័យខ្ពស់ ឬបានចូលរួមក្នុងសកម្មភាពដែលមានហានិភ័យខ្ពស់ ត្រូវធ្វើស្វ័យប្រកាស និងត្រូវស្ម័គ្រចិត្តបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញ ក្នុងរយៈពេលកំណត់ណាមួយ តាមការសម្រេចចិត្តរបស់គ្រឹះស្ថាននីមួយៗ និងតាមការចាំបាច់។

## ទី១០. ការត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការផ្អាកដំណើរការជាបណ្តោះអាសន្នគ្រឹះស្ថានឧត្តមសិក្សា និងថ្នាក់ ប្រសិនបើមានការឆ្លងកូវីដ-១៩

- ករណីមានការផ្ទុះឡើង ឬការឆ្លងរាលដាលជំងឺកូវីដ-១៩ ចំពោះបុគ្គលណាមួយដែលធ្លាប់មាន ឬកំពុងមានវត្តមាននៅក្នុងបរិវេណនៃគ្រឹះស្ថាននីមួយៗ គណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាត្រូវចាត់វិធានការឆ្លើយតបជាបន្ទាន់ ដូចជាការផ្អាកដំណើរការគ្រឹះស្ថានជាបណ្តោះអាសន្ន និងធ្វើចត្តាឡីស័ក ១៤ថ្ងៃចំពោះអ្នកពាក់ព័ន្ធ និងការស្វែងរកដំណោះស្រាយណាមួយ ដោយមានការណែនាំពីភ្នាក់ងារសុខាភិបាល និងត្រូវផ្តល់ព័ត៌មានជូនក្រសួងអប់រំ យុវជន និងកីឡា
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដានព័ត៌មានលើប្រវត្តិនៃការធ្វើដំណើរ និងការប៉ះពាល់នៃបុគ្គលសង្ស័យ (Contact tracing) ។

## ទី១១. ក្រសួងអប់រំ យុវជន និងកីឡានឹងពិនិត្យសំណើ និងចុះអនុស្សារណៈនៃការយោគយល់ជាមួយគ្រឹះស្ថានឧត្តមសិក្សា

- គ្រឹះស្ថានឧត្តមសិក្សាត្រូវដាក់សំណើស្តីពីការសាកល្បងបើកដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិនិងការស្រាវជ្រាវ មកកាន់ក្រសួងអប់រំ យុវជន និងកីឡា ដោយភ្ជាប់ជាមួយនូវ ៖
    - ក. អនុស្សារណៈនៃការយោគយល់ ស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ និងឯកសារឧបសម្ព័ន្ធទាំងអស់
    - ខ. ឯកសារស្តីពីការរៀបចំយន្តការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន ផែនការសិក្សា (ការបែងចែកម៉ោងចូលរៀន ម៉ោងសម្រាក ម៉ោងចេញពីគ្រឹះស្ថាន) បំណែងចែកនិស្សិតតាមចំនួនកំណត់ ហេដ្ឋារចនាសម្ព័ន្ធទន់និងរឹងសម្រាប់ដំណើរការបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញ ពិធីសារនៃការអនុវត្តប្រតិបត្តិនៅក្នុងមន្ទីរពិសោធន៍ ឬសាលសហសិក្សា ពិធីសារនៃដំណើរការស្រាវជ្រាវ

គ. ឯកសារស្តីពីវិសាលភាព ផែនការអនុវត្តដោយមានកាលបរិច្ឆេទកំណត់ និងលំដាប់លំដោយនៃការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ ទៅតាមកម្មវិធីបណ្តុះបណ្តាល ឆ្នាំសិក្សា ឬក្រុមនិស្សិត (ប្រសិនបើចាំបាច់)។

- គ្រប់ឯកសារទាំងអស់ ដែលពាក់ព័ន្ធនឹងការស្នើសុំបើកដំណើរការបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ របស់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវចម្លងជូនរដ្ឋបាលរាជធានី-ខេត្ត ឱ្យបានជ្រាបជាព័ត៌មាន។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន លោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

  **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សារណៈនៃការយោគយល់គ្នា
# ស្ដីពី
# ការបើកដំណើរការឡើងវិញ
# នៃគ្រឹះស្ថានឧត្តមសិក្សាឯកជន

រវាង

ក្រសួងអប់រំ យុវជន និងកីឡា

និង

.........................................................................

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**អនុស្សរណៈនៃការយោគយល់**
**ស្ដីពីការបើកដំណើរការឡើងវិញ**
**នៃគ្រឹះស្ថានឧត្ដមសិក្សាឯកជន**

ត្រូវបានធ្វើឡើងនៅថ្ងៃទី.........ខែ...............ឆ្នាំ២០២១(តទៅហៅកាត់ថា " **អនុស្សរណៈ** " ) រវាង៖

**ក្រសួងអប់រំ យុវជន និងកីឡា** (តទៅហៅកាត់ថា «ភាគីក្រសួង»)
និង
........................................សាខា.....................ដែលមានអាសយដ្ឋាន.............................................
.................................................................................................. (តទៅត្រូវហៅថា «ភាគីគ្រឹះស្ថានសិក្សា» )

**បុព្វកថា**

**ដោយមានទស្សនវិស័យ** ក្នុងការជំរុញឲ្យមានការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់សិស្សានុសិស្ស និងប្រជាជនកម្ពុជាទាំងអស់គ្នានៅទូទាំង ព្រះរាជាណាចក្រកម្ពុជា។

**ដោយមានគោលបំណង** លើកកម្ពស់ និងចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តវិធានការចាំបាច់ដើម្បីគ្រប់គ្រង បង្ការ និងចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅរក្សាសុខភាព សុខមាលភាព និងសុវត្ថិភាព សម្រាប់អ្នកសិក្សា និងបុគ្គលិកអប់រំគ្រប់រូប។

**ដោយមានការពិភាក្សា** វិភាគ និងគិតគូរពិចារណាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ រវាងអ្នកជំនាញការអប់រំ អ្នកជំនាញការសុខភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ មាតាបិតា និងអ្នកអាណាព្យាបាល ដោយមានការថ្លឹងថ្លែងហេតុផល ស្ដីពីវិធានការចាំបាច់បំផុត និងចំណាត់ការទាំងឡាយដែលគ្រឹះស្ថានសិក្សាត្រូវរៀបចំដើម្បីធានាសុវត្ថិភាពខ្ពស់បំផុត និងអនាម័យល្អបំផុត ជូនចំពោះអ្នកសិក្សា និង បុគ្គលិកអប់រំ ។

**ដោយមានការត្រៀមខ្លួនរួចជាស្រេច** ពី «ភាគីគ្រឹះស្ថានសិក្សា» ក្នុងការសហការជាមួយ «ភាគីក្រសួង» អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធ ក្នុងការស្វែងរកដំណោះស្រាយដ៏ល្អប្រសើរមួយ ដោយដាក់សុវត្ថិភាព សុខភាព និងសុខុមាលភាពអ្នកសិក្សា និងបុគ្គលិកអប់រំ ជាអាទិភាពបំផុត ក្នុងដំណាក់កាលនៃការបើកដំណើរការឡើងវិញដោយសាកល្បង នៃគ្រឹះស្ថានឧត្ដមសិក្សា។

**ដោយមានការយល់ព្រមជាឯកច្ឆន្ទ** ពី «ភាគីគ្រឹះស្ថានសិក្សា» ថាសុខចិត្តទទួលខុសត្រូវគ្រប់បែបយ៉ាង នៅចំពោះមុខច្បាប់ និងវិធានការចាំបាច់នានារបស់អាជ្ញាធរមានសមត្ថកិច្ច ចំពោះគ្រប់ហានិភ័យដែល

នឹងអាចកើតឡើងជាយថាហេតុ នៃការផ្ទុះឡើង និងការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការសម្រេចចិត្តសាកល្បងបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សា ។

## "ភាគីគ្រឹះស្ថានសិក្សា" ព្រមព្រៀងជាមួយ "ភាគីក្រសួង" ក្នុងការគោរពអនុស្សារណៈដែលមានខ្លឹមសារដូចតទៅ

## ប្រការ១
## គោលបំណង និងវិសាលភាពនៃអនុស្សារណៈ

១.១ អនុស្សរណៈនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងកំណត់ពីក្របខណ្ឌនៃការរៀបចំ ការប្រតិបត្តិ និង ការទទួលខុសត្រូវនៃក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកអប់រំ ក្នុងការអនុវត្តវិធានការសុវត្ថិភាព និងស្តង់ដាអនាម័យសម្រាប់គ្រប់គ្រង បង្ការ និងទប់ស្កាត់ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងដំណាក់កាលនៃការសាកល្បងបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សា .................................... .......................... ដែលមានអាសយដ្ឋាន ..........................................................................................................................................

១.២ អនុស្សារណៈនេះ មានវិសាលភាពគ្របដណ្តប់ទៅលើសកម្មភាពទាំងឡាយ ក្នុងការរៀបចំ ការប្រតិបត្តិ និងការទទួលខុសត្រូវនៃក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកអប់រំ ក្នុងការអនុវត្តលក្ខខណ្ឌតម្រូវនៃការលើកកម្ពស់សុខភាពសិក្សា សម្រាប់គ្រប់គ្រង បង្ការ និងទប់ស្កាត់ ការផ្ទុះឡើងនិងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដើម្បីធានាសុវត្ថិភាព សុខភាព និងសុខុមាលភាពអ្នកសិក្សា និងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សា ........................................................ ដែលមានអាសយដ្ឋាន........................................................................................................

១.៣ អនុស្សារណៈនេះ ធ្វើឡើងដោយស្របតាមស្មារតី ខ្លឹមសារ និងការអនុវត្តនៃលិខិតបទដ្ឋានគតិយុត្តិជាធរមាន ដែលបានរៀបចំដោយរាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងការគ្រប់គ្រង បង្ការ និងទប់ស្កាត់ ការផ្ទុះឡើងនិងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## ប្រការ២
## នីតិានុវត្តន៍ស្ថាប័នដើម្បីសាកល្បងដំណើរការគ្រឹះស្ថានសិក្សា

២.១ "ភាគីគ្រឹះស្ថានសិក្សា" ត្រូវធ្វើនីតិានុវត្តលើការរៀបចំ និងដំណើរការស្ថាប័នគ្រឹះស្ថានសិក្សា ដោយមានការ រៀបចំឯកសារពាក់ព័ន្ធដូចខាងក្រោម (ចាប់ពីពេលនេះតទៅ ត្រូវហៅថា "ឯកសារឧបសម្ព័ន្ធ")៖

២.១.១ គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩ (ឧបសម្ព័ន្ធទី១)

២.១.២ ពិធីសារនៃការអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ សម្រាប់និស្សិតដែលរៀនក្នុងថ្នាក់ដោយផ្ទាល់ និងរៀនតាមប្រព័ន្ធអនឡាញ (ឧបសម្ព័ន្ធទី២)

២.១.៣ ពិធីសារនៃការរៀបចំកាលវិភាគសិក្សា ដែលបង្ការភាពកកកុញ និងការជាន់គ្នា (Staggered entry) ដោយកំណត់ចំនួនសិស្ស ឬនិស្សិតមានវត្តមានក្នុងទីធ្លាសាលា ដើម្បីរក្សាសុវត្ថិភាពបុគ្គល (ឧបសម្ព័ន្ធទី៣)

២.១.៤ ពិធីសារនៃការរៀបចំបន្ទប់រៀន ដោយគិតគូរប្រកបដោយសុភវិនិច្ឆ័យ និងការទទួលខុសត្រូវខ្ពស់បំផុត នូវចំនួននិស្សិត សមមាត្រនឹងទំហំបន្ទប់រៀន (ដោយមានសូចនាករអប្បបរមា ១,៥ម៉ែត្រការ៉េសម្រាប់និស្សិតម្នាក់ ហើយបន្ទប់រៀនមួយ មានវត្តមាន ស្សិត និងបុគ្គលិកអប់រំមិនលើស២០ នាក់ (ឧបសម្ព័ន្ធទី៤)

២.១.៥ លិខិតធានាអះអាងលើកិច្ចព្រមព្រៀងរវាងគ្រឹះស្ថានសិក្សា ជាមួយនិស្សិត មាតាបិតា និងអ្នកអាណាព្យាបាល បុគ្គលិកអប់រំ និងបុគ្គលពាក់ព័ន្ធទាំងអស់ ស្តីពីសោហ៊ុយចំណាយសម្រាប់ការធ្វើតេស្ត និងសោហ៊ុយចំណាយសម្រាប់ការព្យាបាលអ្នកជំងឺប្រសិន បើមានការរកឃើញករណីជំងឺកូវីដ-១៩ (ឧបសម្ព័ន្ធទី៦)

២.១.៦ តារាងស្វ័យវាយតម្លៃនៃគ្រឹះស្ថានសិក្សា លើលទ្ធភាពនៃការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ ក្នុងបរិបទនៃជំងឺកូវីដ-១៩ និងការអនុវត្តកម្មវិធីអប់រំពីចម្ងាយ និងការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក (ឧបសម្ព័ន្ធទី៧)

២.២ «ឯកសារឧបសម្ព័ន្ធ» ដូចមានចែងក្នុងចំណុចទី២.១ នៃប្រការ២ នៃអនុស្សារណៈនេះ ត្រូវធ្វើឡើងដោយមានវិសេសភាព និងភាពជាក់លាក់បំផុត សម្រាប់អនុវត្តក្នុងបរិបទនៃទីតាំង............... .................... ដែលមានអាសយដ្ឋាន.............................................................................. ..........................................................................

២.៣ «ភាគីគ្រឹះស្ថានសិក្សា» សូមទទួលស្គាល់ និងទទួលយកថា ភាពខ្វះចន្លោះ ពុំគ្រប់គ្រាន់ ពុំគ្រប់ជ្រុងជ្រោយ ឬចន្លោះប្រហោងនៃការរៀបចំ តាក់តែង និងបង្កើត«ឯកសារឧបសម្ព័ន្ធ» ដូចមានចែងក្នុងចំណុចទី២.១ និង២.២ នៃប្រការ២ និងវិធានទាំងឡាយដែលមានចែងក្នុងអនុស្សារណៈនេះ គឺជាការទទួលខុសត្រូវចំពោះមុខច្បាប់ ដោយ «ភាគីគ្រឹះស្ថានសិក្សា»

២.៤ «ភាគីគ្រឹះស្ថានសិក្សា» សូមទទួលស្គាល់ និងទទួលយកថា ភាពខ្វះចន្លោះ ពុំគ្រប់គ្រាន់ ពុំគ្រប់ជ្រុងជ្រោយ ឬចន្លោះប្រហោងនៃការអនុវត្ត ប្រតិបត្តិ និងអនុលោមទៅតាម «ឯកសារឧបសម្ព័ន្ធ» ដូចមានចែងក្នុងចំណុចទី២.១ និង២.២ នៃប្រការ២ និងវិធានទាំងឡាយដែលមានចែងក្នុងអនុស្សារណៈនេះ គឺជាការទទួលខុសត្រូវ របស់ «ភាគីគ្រឹះស្ថានសិក្សា»

២.៥ «ឯកសារឧបសម្ព័ន្ធ» ដូចមានចែងក្នុងចំណុចទី២.១ និង២.២ នៃប្រការ២ នៃអនុស្សារណៈនេះ ត្រូវធ្វើឡើងជាភាសាខ្មែរ ហើយអាចបកប្រែជាភាសាបរទេសផ្សេងទៀតតាមការចាំបាច់របស់ «ភាគីគ្រឹះស្ថានសិក្សា»

២.៦ «ឯកសារឧបសម្ព័ន្ធ» ដូចមានចែងក្នុងប្រការ២.១ គឺជាឧបសម្ព័ន្ធនៃអនុស្សារណៈនេះ

២.៧ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវបន្តរៀបចំ កែលម្អ និងធ្វើឲ្យកាន់តែប្រសើរឡើង នូវប្រព័ន្ធនៃការអប់រំឌីជីថល និងការអប់រំពីចម្ងាយ រួមមានការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិកត្រូនិក ការផលិត និងការបង្ហោះមាតិកាឌីជីថល និងការពង្រឹងវេទិកាឌីជីថល ដើម្បីផ្តល់ជាជម្រើសសម្រាប់ការរៀនជូនដល់និស្សិតដែលពុំមានវត្តមាននៅគ្រឹះស្ថានសិក្សា។

## ប្រការ៣
## ការផ្សព្វផ្សាយជាសាធារណៈនូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទ នៃជំងឺកូវីដ-១៩

៣.១ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវផ្សព្វផ្សាយខ្លឹមសារនៃ «គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩» ដូចមានចែងក្នុងចំនុចទី ២.១.១ នៃប្រការ២ នៃអនុស្សរណៈនេះ ដែលរៀបចំបង្កើតឡើងដោយ «ភាគីគ្រឹះស្ថានសិក្សា» នៅទីតាំងដែលគ្មានការបិទបាំងពីគំហើញជាសាធារណៈ ឲ្យបានយ៉ាងតិចចំនួន៣កន្លែង។

៣.២ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវផ្ញើរជូនមាតាបិតានិងអ្នកអាណាព្យាបាល នូវខ្លឹមសារនៃអនុស្សរណៈនេះ និង ខ្លឹមសារនៃ «គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩» ដូចមានចែងក្នុងចំនុចទី២.១.១ នៃប្រការ២ នៃអនុស្សរណៈនេះ ហើយត្រូវស្នើសុំឲ្យមាតាបិតា និងអ្នកអាណាព្យាបាល អានពិនិត្យ និងចុះហត្ថលេខាទទួលស្គាល់។

៣.៣ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវស្នើសុំឲ្យអ្នកសិក្សា អាន និងពិនិត្យខ្លឹមសារនៃ «គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ-១៩» ដូចមានចែងក្នុងចំណុចទី២.១.១ នៃប្រការ២ នៃអនុស្សរណៈនេះ និងចុះហត្ថលេខាទទួលស្គាល់។

៣.៤ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវអនុវត្តស្មារតីនៃ ចំណុចទី៣.១ ចំណុចទី៣.២ និងចំណុចទី៣.៣ នៃប្រការ ៣ នៃអនុស្សារណៈនេះ នៅគ្រប់ពេលនៃការចាប់ផ្តើមដំបូងនៃកម្មវិធីសិក្សា វគ្គសិក្សា និងឆ្នាំសិក្សា។ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវបញ្ជូនរបាយការណ៍ស្តីពីសកម្មភាពក្នុងការអនុវត្តតាមស្មារតីនៃប្រការ៣ នៃអនុស្សរណៈនេះ មកក្រសួងអប់រំ យុវជន និងកីឡា យ៉ាងយូរត្រឹម១សប្តាហ៍បន្ទាប់ពីចាប់ផ្តើមដំណើរការកម្មវិធីសិក្សា វគ្គសិក្សា និងឆ្នាំសិក្សា។

## ប្រការ៤
## ការស្នើសុំ ការរៀបចំ និងការរក្សាទុកកំណត់ត្រាស្តីពីប្រវត្តិនៃការធ្វើដំណើរ និងការប្រាស្រ័យទាក់ទង

៤.១ «ភាគីសាលារៀន» ត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងប្រវត្តិនៃការធ្វើដំណើរ និងការប្រាស្រ័យទាក់ទង ដែលពាក់ព័ន្ធនឹងអ្នកសិក្សា មាតាបិតានិងអ្នកអាណាព្យាបាល និងបុគ្គលិកអប់រំទាំងអស់ ៖

៤.១.១ ប្រវត្តិនៃការធ្វើដំណើររបស់អ្នកសិក្សា មាតាបិតានិងអ្នកអាណាព្យាបាល និងបុគ្គលិកអប់រំទាំងអស់ ក្នុងអំឡុងពេល២ខែមុនការចាប់ផ្តើមដំណើរការសាលារៀនសាជាថ្មី និងជាបន្តបន្ទាប់ទៀតជាប្រចាំ។

៤.១.២ កំណត់ត្រានៃការជួបប្រាស្រ័យទាក់ទងដោយផ្ទាល់មុខ ជាមួយអ្នកដែលមានការពាក់ព័ន្ធនឹងការធ្វើដំណើរ ឬមានធុរកិច្ចជាមួយមនុស្សនៅប្រទេសដែលផ្ទុះជំងឺកូវីដ-១៩ ក្នុងអំឡុងពេល១ខែមុនការចាប់ផ្តើមដំណើរការគ្រឹះស្ថានសិក្សាសាជាថ្មី និងជាបន្តបន្ទាប់ទៀតជាប្រចាំ។

## ប្រការ៥
## ការអនុវត្តខ្លឹមសារ "ឯកសារឧបសម្ព័ន្ធ"

៥.១ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវអនុវត្តខ្លឹមសារនៃពិធីសារអនាម័យ ប្រកបដោយភាពហ្មត់ចត់ ច្បាស់លាស់ ស្មើភាព និងតម្លាភាពបំផុត។ គ្មានអ្នកសិក្សា ឬបុគ្គលិកអប់រំរូបណា ដែលអាចគេចផុត ឬទទួលការលើកលែងពីការអនុវត្ត «ឯកសារឧបសម្ព័ន្ធ» ឡើយ វៀរលែងតែមានករណីពិសេសដែលត្រូវមានការបញ្ជាក់ពីភ្នាក់ងារឬអាជ្ញាធរមានសមត្ថកិច្ច។

៥.២ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវផ្តល់មធ្យោបាយឲ្យបានគ្រប់គ្រាន់បំផុត សមរម្យបំផុត និងប្រកបដោយភាពបរិយាបន្ន ជូនដល់អ្នកសិក្សា និងបុគ្គលិកអប់រំដែលមានតម្រូវការពិសេស (ផ្នែករូបសាស្ត្រ ចិត្តសាស្ត្រ ឬសរីរសាស្ត្រ) ដើម្បីចូលរួមអនុវត្តខ្លឹមសារ និងស្មារតីនៃ «ឯកសារឧបសម្ព័ន្ធ»។

៥.៣ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវចាត់ទុកការអនុវត្ត និងការបំពេញប្រតិបត្តិលើ «ឯកសារឧបសម្ព័ន្ធ» របស់អ្នកសិក្សា ថាជាផ្នែកមួយ និងជាលក្ខខណ្ឌចាំបាច់នៃកម្មវិធីសិក្សា។

៥.៤ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវអនុញ្ញាតជូនប្រតិភូ ឬអ្នកតំណាងរបស់ «ភាគីក្រសួង» ចុះត្រួតពិនិត្យដោយមាន ឬដោយពុំមានការជម្រាបជូនជាមុន លើការអនុវត្តខ្លឹមសារនៃអនុស្សារណៈនេះ។ ក្នុងករណីនេះ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវស្នើសុំឲ្យប្រតិភូ ឬអ្នកតំណាងរបស់ «ភាគីក្រសួង» បង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ហើយត្រូវផ្តល់កិច្ចសហការឲ្យបានពេញលេញបំផុត។

## ប្រការ៦
## ការបំពេញបន្ថែមលើការអនុវត្តខ្លឹមសារ និងស្មារតីនៃ "ឯកសារឧបសម្ព័ន្ធ"

៦.១ ការអនុវត្តខ្លឹមសារនិងស្មារតីនៃអនុស្សារណៈនេះ ជាការបំពេញបន្ថែមទៅលើបណ្តាក្របខណ្ឌគតិយុត្តិ និងវិធានការផ្សេងៗទៀតដែលមានជាធរមាន។

៦.២ ក្នុងករណីខ្លឹមសារទាំងមូល ឬដោយផ្នែកនៃអនុស្សារណៈ និង "ឯកសារឧបសម្ព័ន្ធ" មានប្រតិសកម្មទៅលើក្របខណ្ឌគតិយុត្តិ និងវិធានការផ្សេងៗទៀតដែលមានជាធរមាន "ភាគីគ្រឹះស្ថានសិក្សា" ត្រូវជម្រាបជាលាយលក្ខណអក្សរមកកាន់ "ភាគីក្រសួង" យ៉ាងយូរបំផុត៣ថ្ងៃក្រោយការរកឃើញជាតុនៃប្រតិសកម្ម។

៦.៣ ក្នុងករណីផលវិបាកនៃការអនុវត្តខ្លឹមសារទាំងមូល ឬដោយផ្នែកនៃអនុស្សរណៈ និង "ឯកសារឧបសម្ព័ន្ធ" មានប្រតិឃាតទៅលើក្របខណ្ឌគតិយុត្តិ និងវិធានការផ្សេងៗទៀតដែលមានជាធរមាន "ភាគីគ្រឹះស្ថានសិក្សា" ត្រូវជម្រាបជាលាយលក្ខណអក្សរមកកាន់ "ភាគីក្រសួង" យ៉ាងយូរបំផុត១ថ្ងៃក្រោយការរកឃើញផលវិបាកនៃប្រតិឃាត។

## ប្រការ៧
## ការកែសម្រួលខ្លឹមសារនៃអនុស្សារណៈ

៧.១ គ្មានផ្នែកទាំងមូល ឬផ្នែកណាមួយនៃអនុស្សរណៈ និង "ឯកសារឧបសម្ព័ន្ធ" ត្រូវបានកែសម្រួលជាដាច់ខាត ដោយ "ភាគីគ្រឹះស្ថានសិក្សា" ជាឯកតោភាគី។

៧.២ ក្នុងករណីមានតម្រូវការបន្ថែមពីភ្នាក់ងារឬអជ្ញាធរមានសមត្ថកិច្ច ក្នុងការកែសម្រួលខ្លឹមសារទាំងមូលឬដោយផ្នែកនៃអនុស្សារណៈ ឬ "ឯកសារឧបសម្ព័ន្ធ" "ភាគីក្រសួង" នឹងស្នើសុំជាលាយលក្ខណអក្សរទៅកាន់ "ភាគីគ្រឹះស្ថានសិក្សា" ហើយ "ភាគីគ្រឹះស្ថានសិក្សា" នឹងមានពេលវេលាយ៉ាងយូរ១ថ្ងៃ ដើម្បីកែសម្រួលខ្លឹមសារ។

៧.២ ក្នុងករណីមានតម្រូវការបន្ថែមពីភ្នាក់ងារឬអាជ្ញាធរមានសមត្ថកិច្ច ក្នុងការកែសម្រួលខ្លឹមសារទាំងមូលឬដោយផ្នែកនៃអនុស្សរណៈ ឬ "ឯកសារឧបសម្ព័ន្ធ" "ភាគីគ្រឹះស្ថានសិក្សា" ត្រូវអនុវត្តខ្លឹមសារនៃប្រការ៣ទាំងមូលនៃអនុស្សារណៈនេះសាជាថ្មី។

## ប្រការ៨
## ការធ្វើតេស្តពិនិត្យបត្តមានមេរោគនៃជំងឺកូវីដ-១៩

៨.១ "ភាគីគ្រឹះស្ថានសិក្សា"ត្រូវធ្វើតេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ លើអ្នកសិក្សា និងបុគ្គលិកអប់រំ ដែល

ត្រូវមានវត្តមានក្នុងបរិវេណគ្រឹះស្ថានសិក្សាដែលមានទីតាំងដូចមានចែងក្នុងចំណុចទី១.១ និង១.២ នៃប្រការ១ នៃអនុស្សរណៈនេះ (ដោយទាក់ទងដោយផ្ទាល់ទៅកាន់រដ្ឋបាល រាជធានី-ខេត្ត ឬដោយស្ថាប័នផ្ទាល់ខ្លួន) មុនពេលដំណើរការសាកល្បងបង្រៀននិងរៀន ការអនុវត្តប្រតិបត្តិ និងការស្រាវជ្រាវ

៨.២ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវរៀបចំផែនការធ្វើតេស្តហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយចៃដន្យ និងជាប្រចាំសម្រាប់អ្នកសិក្សា និងបុគ្គលិកអប់រំ ដែលត្រូវមានវត្តមានក្នុងបរិវេណគ្រឹះស្ថានសិក្សា ដែលមានទីតាំងដូចមានចែងក្នុងចំណុចទី១.១ និង១.២ នៃប្រការ១ នៃអនុស្សារណៈនេះ តាមលទ្ធភាពធនធានជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា

៨.៣ «ភាគីគ្រឹះស្ថានសិក្សា» នឹងពិភាក្សា និងស្វែងរកកិច្ចព្រមព្រៀងលើសោហ៊ុយចំណាយសម្រាប់ការធ្វើតេស្ត និងសោហ៊ុយចំណាយសម្រាប់ការថែទាំព្យាបាលអ្នកជំងឺ ប្រសិនបើមានការរកឃើញករណីជំងឺកូវីដ-១៩ ជាមួយអ្នកសិក្សានិងបុគ្គលិកអប់រំ

## ប្រការ៩
## មន្ត្រីបង្គោលសម្រាប់ការទាក់ទង

៩.១ ក្នុងករណី «ភាគីគ្រឹះស្ថានសិក្សា» មានបំណងបញ្ជាក់ពីការជូនដំណឹង ការឯកភាពយល់ព្រម ការទាមទារ ឬការប្រាស្រ័យទាក់ទងផ្សេងៗ ដែលធ្វើឡើងក្រោមក្របខណ្ឌនៃអនុស្សរណៈនេះ «ភាគីគ្រឹះស្ថានសិក្សា» ត្រូវធ្វើដោយយកភាសាខ្មែរជាភាសាគោល ហើយត្រូវផ្ញើចេញពីអាសយដ្ឋានដែលបានកំណត់ក្នុងអនុស្សារណៈនេះ។

៩.២ ដើម្បីជាមធ្យោបាយប្រាស្រ័យទាក់ទង «ភាគីគ្រឹះស្ថានសិក្សា» សូមកំណត់មន្ត្រីបង្គោលចំនួន២រូប ក្នុងការទាក់ទងព័ត៌មាន ដូចខាងក្រោម ៖

លោកស្រី/លោក ...............................
តួនាទី.........................................
ទូរស័ព្ទ ......................................
អ៊ីម៉េល .......................................

លោកស្រី/លោក ..............................
តួនាទី........................................
ទូរស័ព្ទ .....................................
អ៊ីម៉េល ......................................

## ប្រការ១០
## សុពលភាព

១០.១ អនុស្សារណៈនេះមានសុពលភាពក្នុងការអនុវត្តជាបន្ទាន់ ចាប់ពីថ្ងៃចុះហត្ថលេខាទទួលស្គាល់ដោយរដ្ឋមន្ត្រី នៃក្រសួងអប់រំ យុវជន និងកីឡា។

១០.២ «ភាគីគ្រឹះស្ថានសិក្សា» សូមព្រមព្រៀងអនុវត្តខ្លឹមសារនៃអនុស្សរណៈនេះ រហូតដល់ថ្ងៃណាមួយដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសជាផ្លូវការថាពុំមានការគំរាមកំហែង ឬហានិភ័យនៃការផ្ទុះឡើងនិងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩តទៅទៀត។

១០.៣ ក្នុងករណីជំងឺកូវីដ-១៩រាតត្បាតខ្លាំង និងមានការប្រកាសអាសន្នរបស់រាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាល ឬអង្គការសុខភាពពិភពលោក អនុស្សារណៈនេះនឹងត្រូវផ្អាកដោយស្វ័យប្រវត្តិ។

**ដើម្បីជាសក្ខីភាពបញ្ជាក់ពីសុឆន្ទៈ** ក្នុងការយល់ព្រមទាំងស្រុងលើខ្លឹមសារនៃអនុស្សរណៈនេះ «ភាគីគ្រឹះស្ថានសិក្សា» និង «ភាគីក្រសួង» សូមចុះហត្ថលេខាលើអនុស្សរណៈនេះជាពីរច្បាប់ ដោយតម្កល់មួយច្បាប់ដោយ «ភាគីគ្រឹះស្ថានសិក្សា» និងមួយច្បាប់ទៀតសម្រាប់ប្រគល់ជូន «ភាគីក្រសួង» ។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**តំណាងក្រសួងអប់រំ យុវជន និងកីឡា** **តំណាងគ្រឹះស្ថានសិក្សា**

# ឧបសម្ព័ន្ធទី១

## គំរូមាគគានៃគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទ នៃជំងឺកូវីដ-១៩

### ១. ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

- ការបង្កើត **គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា** ដោយកំណត់សមាសភាព និងភារកិច្ចច្បាស់លាស់
- ការដាក់បញ្ចូល និងពង្រឹងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពសិក្សា ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សានីមួយៗ រួមទាំង**ការរៀបចំ និងដំណើរការបន្ទប់សុខភាព**
- ការបញ្ជាក់ពីការស្វែងយល់ និងផ្សព្វផ្សាយសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាល ក្រសួងការបរទេសនិងទំនាក់ទំនងអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងការលើកកម្ពស់សុខភាព ការបង្ការជំងឺ ឬការបង្ការគ្រោះថ្នាក់នានាដែលក្រសួង បានដាក់ចេញនាពេលកន្លងមក ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

### ២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសិក្សា

#### ២.១ ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព

- ការរក្សាសីតុណ្ហភាពក្នុងបន្ទប់រៀនមិនទាបជាង ២៤ អង្សាសេ
- ការអនុវត្តវិធានរម្ងាប់មេរោគ មុននឹងដាក់ឱ្យដំណើរការគ្រឹះស្ថានសិក្សា ជាពិសេសបន្ទប់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ អគារ សួនកម្សាន្តរបស់កុមារ និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ
- ការធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារ និងបរិវេណគ្រឹះស្ថានសិក្សា និងត្រូវគ្រប់គ្រងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ
- ការសម្អាត ឬរម្ងាប់មេរោគឱ្យបានញឹកញាប់នៅតាមកន្លែង ឬផ្ទៃលើនៃវត្ថុ ដែលអាចមានមនុស្សច្រើន ប៉ះពាល់ដូចជា ដៃទ្វារ តុ កៅអី។ល។
- ការបើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា
- ការពាក់ម៉ាស់ ពាក់ស្រោមដៃ និងស្បែកជើងឱ្យបានត្រឹមត្រូវមុនពេល និងក្នុងពេលសម្អាត ចំពោះអ្នកទទួលខុសត្រូវការសម្អាត
- **ការវាយតម្លៃពីការសម្អាតបរិស្ថានគ្រឹះស្ថានសិក្សា ដើម្បីធានាថាពុំមានការឆ្លងជំងឺកូវីដ-១៩ ទៅដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត**

## ២.២ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាគម្លាតសុវត្ថិភាព ក្នុងគ្រឹះស្ថានសិក្សា

- ការរៀបចំតុ កៅអីអង្គុយសម្រាប់សិស្សានុសិស្សនៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច២ម៉ែត្រ និងរៀបចំចំណុះថ្នាក់ ដោយកំណត់សិស្សមិនលើសពី២០នាក់ក្នុង១ថ្នាក់
- ការបើកច្រកទ្វារចេញចូលក្នុងបរិវេណគ្រឹះស្ថានសិក្សាទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើនកកកុញតាមច្រកចេញចូល ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី១,៥ម៉ែត្រឡើងទៅ នៅច្រកទ្វារចូលគ្រឹះស្ថានសិក្សា
- ការរៀបចំការគោរពទង់ជាតិក្នុងទ្រង់ទ្រាយតូចជាតំណាង ដើម្បីជានាគម្លាតសុវត្ថិភាព ដោយធ្វើការផ្លាស់វេនតាមថ្នាក់
- ការបែងចែកវេនសិស្សមួយចំនួននៅក្នុងបន្ទប់ និងមួយចំនួនចេញក្រៅបន្ទប់រៀន នៅពេលចេញលេងម្តងៗ ព្រមទាំងត្រូវជានាគម្លាតសុវត្ថិភាពពេលចូលប្រើប្រាស់បង្គន់អនាម័យ ឬកន្លែងលាងសម្អាតដៃ
- ត្រូវរៀបចំកាលវិភាគចេញពីគ្រឹះស្ថានសិក្សាម្តងមួយថ្នាក់ៗតាមលំដាប់លំដោយ នៅពេលចប់ម៉ោងសិក្សាចេញទៅផ្ទះ
- ការផ្អាកដំណើរការបណ្ណាល័យ និងមិនត្រូវឱ្យមានការខ្ចីសៀវភៅគ្នាទៅវិញទៅមក
- ការបិទទ្វាររបងគ្រឹះស្ថានសិក្សា ព្រមទាំងចាត់តាំងការយាមកាមឱ្យបានហ្មត់ចត់ អំឡុងពេលម៉ោងសិក្សា ដោយមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញចូលឡើយ
- ការចៀសវាងការប្រមូលផ្តុំគ្រប់រូបភាព ទាំងអំឡុងពេលម៉ោងសិក្សា ឬក្រៅម៉ោងសិក្សា
- ការរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច១,៥ម៉ែត្រឡើងទៅនៅក្នុងថ្នាក់រៀន និង២ម៉ែត្រឡើងទៅនៅទីធ្លាលំហ ក្នុងបរិវេណគ្រឹះស្ថានសិក្សា
- ការផ្អាកកន្លែងកំសាន្ត ឬទីលានកីឡា ដែលមានលក្ខណៈប្រមូលផ្តុំក្នុងបរិវេណគ្រឹះស្ថានសិក្សាជាបណ្តោះអាសន្ន
- ការហាមឃាត់ការរៀបចំព្រឹត្តិការណ៍សហគមន៍ ឬការជួបជុំណាមួយនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ដើម្បីចៀសវាងហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩

## ២.៣ ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត

- ការអប់រំ ផ្សព្វផ្សាយដល់សិស្សានុសិស្ស និស្សិត និងបុគ្គលិកអប់រំ ស្តីពីការបង្កើតទម្លាប់រស់នៅធម្មតាតាមគន្លងថ្មី ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការសុវត្ថិភាពសុខភាព
- ការរៀបចំបន្ទប់សុខភាព និងចាត់តាំងឱ្យមានគ្រូទទួលបន្ទុកសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ សម្រាប់ការសង្គ្រោះបឋម ការពិនិត្យសុខភាពជូនអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា

- ការណែនាំឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា បំពេញព័ត៌មានសុខភាព និងប្រវត្តិធ្វើដំណើរមកពីក្រៅប្រទេស ដើម្បីពិនិត្យតាមដាននិងរក្សាទុកឯកសារ
- ការណែនាំមាតាបិតា អ្នកអាណាព្យាបាល ផ្តល់ព័ត៌មានអំពីសុខភាព និងប្រវត្តិនៃការធ្វើដំណើរក្នុង និងក្រៅប្រទេស និងការជួបជុំដែលអាចបង្កើតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩
- ការចាត់វិធានការវាស់កម្តៅអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សាជាប្រចាំមុនពេលចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា។ ករណីរកឃើញមានកម្តៅចាប់ពី ៣៧.៥ អង្សាសេ ឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងគ្រឹះស្ថានសិក្សាឡើយ ហើយត្រូវណែនាំនិងអនុញ្ញាតឱ្យសម្រាកនៅផ្ទះ ឬទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព
- ការអនុញ្ញាតឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សាឈប់សម្រាក ក្នុងករណីពួកគេមានអាការៈណាមួយដូចជាក្តៅខ្លួនចាប់ពី ៣៧.៥ អង្សាសេ ឡើងទៅ ក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម មានជំងឺផ្លូវដង្ហើម មានរោគសញ្ញាផ្សេងៗទៀតនៃជំងឺឆ្លង ឬមានជំងឺឆ្លងរាតត្បាតនានា ឬអ្នកដែលមានប្រវត្តិធ្វើដំណើរមកពីក្រៅប្រទេស ឬអ្នកធ្លាប់ប៉ះពាល់អ្នកជំងឺកូវីដ-១៩ ដែលមិនទាន់បានធ្វើចត្តាឡីស័ក១៤ថ្ងៃ
- ការរៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចូលសាលា និងពេលចេញពីសាលា ដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់ និងពេលចេញរបស់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត ដើម្បីកុំឱ្យចូល និងចេញក្នុងពេលតែមួយ ទាំងក្នុងបរិវេណគ្រឹះស្ថានសិក្សា និងពេលចូលក្នុងថ្នាក់រៀន។

## ២.៤ ការផ្តល់អាហារូបត្ថម្ភ និងអាហារប្រកបដោយសុវត្ថិភាព

- ការណែនាំ និងផ្សព្វផ្សាយដល់មាតាបិតា ឬអ្នកអាណាព្យាបាល ឱ្យយកចិត្តទុកដាក់រៀបចំចំណីអាហារប្រកបដោយសុវត្ថិភាព និងសុខភាពត្រឹមត្រូវ ដើម្បីជួយដល់សុខភាព និងការលូតលាស់រាងកាយរបស់កូន ក្មួយ ឬចៅ សម្រាប់បរិភោគនៅផ្ទះ និងនៅគ្រឹះស្ថានសិក្សា ជាពិសេសអាហារត្រូវចម្អិនឱ្យបានឆ្អិនល្អ មិនមែនជាសាច់សត្វឈឺ មិនផ្អែមពេក មិនប្រៃពេក និងមានអនាម័យល្អ
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតទាំងអស់ គួរយកចំណីអាហារពីផ្ទះរៀងៗខ្លួន ដើម្បីយកមកទទួលទាននៅតាមគ្រឹះស្ថានសិក្សា
- ការរៀបចំសណ្តាប់ធ្នាប់កន្លែងទទួលទានចំណីអាហារប្រកបដោយអនាម័យជាប់ជាប្រចាំ និងត្រូវកំណត់ឱ្យអ្នកទទួលទានទាំងអស់ស្ថិតនៅឃ្លាតពីគ្នាចាប់ពី១,៥ម៉ែត្រឡើងទៅ ដោយមិនអនុញ្ញាតឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតទទួលទានអាហាររួមគ្នា ឬចែករំលែកចំណីអាហារគ្នា ឬអង្គុយកកកុញក្បែរគ្នានោះឡើយ
- ត្រូវហាមឃាត់ការលក់ចំណីអាហារនៅក្នុង និងក្រៅជាប់របងគ្រឹះស្ថានសិក្សា ។

## ២.៥ ការផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខារអនាម័យ

- ការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងគ្រឹះស្ថានសិក្សា ជូនដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត លើកទឹកចិត្តឱ្យនាំយកទឹកស្អាតពីផ្ទះ សម្រាប់ទុកទទួលទានផ្ទាល់ខ្លួន
- ការរៀបចំបរិក្ខារលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ ឬក្បែរបន្ទប់រៀន ដោយមានសាប៊ូ និងមានទឹកស្អាតប្រើប្រាស់ជាប្រចាំ សមស្របតាមតម្រូវការរបស់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា
- ការរៀបចំបរិក្ខារលាងសម្អាតដៃជាបណ្ដោះអាសន្ន ចំពោះគ្រឹះស្ថានសិក្សាដែលមិនទាន់មានបរិក្ខារលាងសម្អាតដៃ និងត្រូវដាក់វេនសម្អាតឱ្យបានត្រឹមត្រូវជាប្រចាំថ្ងៃ
- ការផ្គត់ផ្គង់ទឹករម្ងាប់មេរោគដូចជា ទឹកអាល់កុល ឬទឹកដែលលាងសម្អាតដៃ សម្រាប់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សាបានប្រើប្រាស់ប្រចាំថ្ងៃ
- ការថែទាំបង្គន់អនាម័យឱ្យស្អាតជាប្រចាំ ដោយមានទឹក សាប៊ូ និងត្រូវបើកឱ្យប្រើប្រាស់រៀងរាល់ម៉ោងសិក្សា ព្រមទាំងបែងចែកបង្គន់សម្រាប់ប្រុស និងបង្គន់សម្រាប់ស្រីដាច់ពីគ្នា ហើយត្រូវដាក់វេនសម្អាតជាច្រើនដងក្នុងមួយថ្ងៃ។

## ២.៦ ការអប់រំសុខភាព និងបណ្ដុះបណ្ដាលអំពីវិធានការបង្ការជំងឺកូវីដ-១៩

- ការបិទផ្សាយរូបភាពផ្ទាំងធំ និងខិតបណ្ណអប់រំសុខភាពនានា ជាពិសេសរបៀបលាងសម្អាតដៃ វិធីការពារ បង្ការជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថានសិក្សា បានច្រើនកន្លែងដែលអាចមើលឃើញនិងយកជាគំរូ
- ការរៀបចំ និងពង្រឹងការអប់រំផ្សព្វផ្សាយខ្លឹមសារសុខភាពសំខាន់ៗពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ឬជំងឺឆ្លងស្រួចស្រាវនានាដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ស្ដីពីសារៈសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថានសិក្សា
- ការប្រើប្រាស់ និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់ និងផ្លូវការ ស្ដីពីស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩ ដូចជាក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ឬក្រសួង
- ការណែនាំអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ឱ្យគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ ដោយមិនត្រូវស្ថិតក្រោមទស្សនៈ "ការភ័យខ្លាច និងការរើសអើង" ដែលអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ

- ការតាមដានមូលហេតុអវត្តមានរបស់បុគ្គលិកអប់រំ អ្នកសិក្សា និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា។ ក្នុងករណីសង្ស័យមានជំងឺផ្លូវដង្ហើម ឬជំងឺឆ្លងនានា ត្រូវជូនដំណឹងទៅមន្ត្រីសុខាភិបាល និងអ្នកពាក់ព័ន្ធដើម្បីចុះអន្តរាគមន៍
- ការហាមឃាត់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតមិនឱ្យធ្វើដំណើរទៅកន្លែងមានអត្រាឆ្លងជំងឺកូវីដ-១៩ និងមិនត្រូវរៀបចំសកម្មភាពណាដែលបង្កឱ្យមានហានិភ័យនៃការចម្លងរោគ
- ការជំរុញ និងណែនាំឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា អនុវត្តវិធានការអនាម័យជាប់ជាប្រចាំ ដោយការលាងសម្អាតដៃឱ្យបានញឹកញាប់ជាមួយទឹកនិងសាប៊ូ យ៉ាងតិច៤០វិនាទី ក្នុងពេលលាងសម្អាតម្តង ជាពិសេសនៅមុនពេលចូលរៀន ពេលចេញលេង និងពេលចេញទៅផ្ទះ
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សាឱ្យរៀបចំនិងយកជាប់តាមខ្លួនជានិច្ចនូវទឹកអាល់កុល ឬទឹកដែលលាងដៃ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ព្រមទាំងពាក់ម៉ាសការពារ នៅគ្រប់ពេលចេញពីផ្ទះ ពេលបំពេញការងារ ពេលធ្វើដំណើរ និងនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ឬអ្នកដទៃទៀតដែលចូលទំនាក់ទំនងជាមួយគ្រឹះស្ថានសិក្សា អនុវត្តការញើសសំបោរ ការខាកស្តោះឱ្យត្រឹមត្រូវនៅបន្ទប់ទឹក ឬបង្គន់អនាម័យ ដោយមិនអនុញ្ញាតឱ្យខាកស្តោះ ឬញើសសំបោរ នៅក្នុងបន្ទប់រៀន បន្ទប់ប្រជុំ បណ្ណាល័យ បន្ទប់ពិសោធន៍ ឬក្នុងបរិវេណគ្រឹះស្ថានសិក្សា
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ ឬបុគ្គលិកបម្រើការផ្សេងទៀតធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អកឬកណ្តាស់ដោយប្រើគន្លាក់កែងដៃឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ
- ការហាមឃាត់អ្នកសិក្សា បុគ្គលិកអប់រំ និង បុគ្គលិកបម្រើការផ្សេងទៀត ប៉ះពាល់គ្នាដោយផ្ទាល់ដូចជាការចាប់ដៃ ឬប្រើប្រាស់របស់របរួមគ្នា និងត្រូវលើកកម្ពស់ការគោរពគ្នា ដោយការសំពះតាមទំនៀមទម្លាប់ខ្មែរ
- ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតចៀសវាងការប៉ះពាល់ជាមួយអ្នកជំងឺ (គ្រុនក្តៅ ក្អក ហៀរសំបោរ ផ្តាសាយ) ក្នុងករណីគ្មានសម្ភារការពារខ្លួន និងមិនត្រូវយកដៃប៉ះភ្នែក ច្រមុះ និងមាត់ឡើយ
- ការផ្អាកជាបណ្តោះអាសន្ននូវសេវាដឹកជញ្ជូនអ្នកសិក្សា ដោយប្រើប្រាស់រថយន្តឬមធ្យោបាយធ្វើដំណើររួមគ្នា រហូតដល់មានការណែនាំជាថ្មី
- ការណែនាំ អ្នកបើកបររថយន្តដឹកសិស្សឱ្យពាក់ម៉ាសការពារជាប់ជាប្រចាំនៅពេលបើកបរ ត្រូវបើកបង្អួច ឬវាំងននឱ្យខ្យល់ចេញចូលបានល្អ ត្រូវអនុវត្តរក្សាគម្លាតកន្លែងអង្គុយដោយទុកចន្លោះ ១កៅអី (នៅពេលទទួលការអនុញ្ញាតជាថ្មីអោយមានសេវានេះ)

- ការពិនិត្យកម្ដៅសិស្សមុនអនុញ្ញាតឱ្យឡើងជិះរថយន្ត។ ប្រសិនបើឃើញថាមានកម្ដៅលើសពី ៣៧.៥អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យសិស្សឡើងជិះរថយន្តនោះទេ។ មុនពេលឡើងជិះរថយន្ត ត្រូវកំណត់ឱ្យសិស្សនិងអ្នកបើកបរលាងសម្អាតដៃនឹងទឹកអាល់កុល ឬទឹកដែលលាងដៃរយៈពេល ២០វិនាទីជាមុនសិន (នៅពេលទទួលការអនុញ្ញាតជាថ្មីអោយមានសេវានេះ)
- ការផ្ដល់ការគាំទ្រផ្នែកសង្គមដល់ អ្នកសិក្សា បុគ្គលិកអប់រំ និង បុគ្គលិកបម្រើការផ្សេងទៀតដើម្បីឱ្យពួកគេចេះទប់ទល់នឹងជំងឺធ្លាក់ទឹកចិត្ត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ ដូចជាការរស់នៅដាច់ដោយឡែក និងការរស់នៅក្នុងកន្លែងដែលមានការរាតត្បាត

## ៣. ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

### ៣.១ អាជ្ញាធរអប់រំ

- ការពង្រឹងកិច្ចសហការរវាងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ឬគណៈកម្មការទ្រទ្រង់គ្រឹះស្ថាន សិក្សា ជាមួយអង្គភាពពាក់ព័ន្ធ មន្ត្រីសុខាភិបាល ដៃគូអភិវឌ្ឍ អាជ្ញាធរមូលដ្ឋាន សហគមន៍ អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីការចូលរួមអនុវត្តតាមសមត្ថកិច្ចរបស់ខ្លួនក្នុងការបង្ការ ទប់ស្កាត់ជំងឺកូវីដ១៩ ឬជំងឺឆ្លងរាតត្បាតផ្សេងទៀតនៅតាមគ្រឹះស្ថានសិក្សា។

### ៣.២ អាជ្ញាធរដែនដី

- ការសហការជាមួយអាជ្ញាធរដែនដី ក្នុងការទទួលបានព័ត៌មានពីហានិភ័យដែលអាចកើតមានឡើងពីការចេញចូលនៃប្រជាជនចំណាកស្រុកនៅតាមមូលដ្ឋាន ឬព័ត៌មានពីការគ្រប់គ្រងអ្នកចំណូលថ្មី ឬព័ត៌មានពីការជួបជុំនានាដែលអាចបង្កហានិភ័យនៃការឆ្លងជំងឺកូវីដ១៩
- ការសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការពិនិត្យលទ្ធភាពស្វែងរកសម្ភារៈ ថវិកាមូលនិធិឃុំ សង្កាត់ ឬពីប្រភពផ្សេងៗទៀត ដើម្បីជួយដល់គ្រឹះស្ថានសិក្សាលើការលើកកម្ពស់សុខភាពសិក្សាពិសេស ផ្ដោតលើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យព្រមទាំងសម្ភារៈអនាម័យដទៃទៀត។

### ៣.៣ ភ្នាក់ងារសុខាភិបាល

- ការពង្រឹងកិច្ចសហការជាមួយអាជ្ញាធរសុខាភិបាលគ្រប់លំដាប់ថ្នាក់ ក្នុងករណីអន្តរាគមន៍បន្ទាន់ និងទាក់ទងទៅលេខ១១៥ ក្នុងករណីសង្ស័យមានជំងឺកូវីដ-១៩ ឬជំងឺឆ្លងរាតត្បាតផ្សេងទៀត
- ការសហការជាមួយមន្ត្រីសុខាភិបាលក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីគាំទ្រនិងតាមដានសុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ ដូចជាប្រើប្រាស់នីតិវិធីរួមក្នុងការផ្ដល់ដំណឹងដល់ប្រព័ន្ធអប់រំក្នុងករណីមានជំងឺឆ្លង ព្រមទាំងរៀបចំវិធានការមូលដ្ឋានចាំបាច់ ក្នុងករណីមានការឆ្លងជំងឺថ្មីៗ
- ការសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីរៀបចំប្រព័ន្ធត្រួតពិនិត្យ និងអធិការកិច្ចជាប្រចាំនៅតាមគ្រឹះស្ថានសិក្សា និងធានាការអនុវត្តវិធានការសុវត្ថិភាពសុខភាពសិក្សា

## ៤. វិធីសាស្ត្រក្នុងការរាយការណ៍អំពីករណីផ្សេងៗ

### ៤.១ ករណីបុគ្គលិកអប់រំ គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្ដៅខ្ពស់

- ការរៀបចំយន្តការ និងនីតិវិធីក្នុងករណីមានការពិនិត្យឃើញថា បុគ្គលិកអប់រំ គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្តៅលើសពី ៣៧,៥ អង្សាសេ អ្នកទាំងនោះមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណសាលា ឬបន្ទប់រៀននោះទេ ហើយត្រូវសហការជាមួយអាជ្ញាធរសុខាភិបាល ដើម្បីទៅរកសេវាព្យាបាលសមស្រប។

### ៤.២ ការធ្វើរបាយការណ៍ទៅមន្ទីរសុខាភិបាល

- ការរៀបចំយន្តការ និងនីតិវិធី ដើម្បីអោយគណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ឬគណៈគ្រប់គ្រងសាលា ជូនដំណឹងដល់មន្ទីរសុខាភិបាលជាបន្ទាន់ ឬតាមរយៈលេខទូរសព្ទទាន់ហេតុការណ៍ ១១៥ ក្នុងពេលមានការរកឃើញករណីសង្ស័យ មានជំងឺកូវីដ១៩។

### ៤.៣ ការរួមសហការឆ្លើយតបជំងឺកូវីដ-១៩

- ការផ្ដល់ឈ្មោះជនបង្គោល និងព័ត៌មានទំនាក់ទំនងជាមួយមន្ត្រីជំនាញសុខាភិបាល ដើម្បីងាយស្រួលទាក់ទងគ្នាចូលរួមអង្កេតស្រាវជ្រាវតាមវិធានការរបស់ក្រសួងសុខាភិបាល និងរួមសហការយ៉ាងជិតស្និទ្ធនិងប្រកបដោយតម្លាភាព ព្រមទាំងផ្ដល់រាល់ព័ត៌មានដែលត្រូវការ ដោយមន្ត្រីជំនាញសុខាភិបាល។

### ៤.៤ ការអនុវត្តវិធានការផ្លូវច្បាប់ ចំពោះការធ្វេសប្រហែស

- ការប្រកាសទទួលស្គាល់ថា អង្គភាពជំនាញនៅថ្នាក់ជាតិ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចគ្រប់គ្រង និងតាមដានការអនុវត្តសេចក្ដីណែនាំនេះ ក្នុងករណីគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាណាពុំបានអនុវត្តតាមដោយយកចិត្តទុកដាក់ និងបណ្ដាលឱ្យមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ១៩ នៅក្នុងគ្រឹះស្ថានសិក្សាជាយថាហេតុ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងនោះ ត្រូវប្រឈមនឹងវិធានការច្បាប់ និងវិធានការរដ្ឋបាលតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន។

### ៤.៥ ការធ្វើរបាយការណ៍

- ការរៀបចំយន្តការ និងនីតិវិធី ដែលគណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ឬគណៈគ្រប់គ្រងសាលា រៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ស្តីពីដំណើរការរបស់គ្រឹះស្ថានសិក្សា និងការអនុវត្តតាមអនុស្សរណៈនៃការយោគយល់គ្នា ឱ្យបានទៀងទាត់មកក្រសួងអប់រំ យុវជន និងកីឡា។

# ឧបសម្ព័ន្ធទី២

## គំរូមាតិកានៃពិធីសារនៃ
## ការអនុវត្តកម្មវិធីអប់រំពីចម្ងាយ និងការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក

**១. ការវាយតម្លៃរហ័សលើស្ថានភាពជាក់ស្តែង** (Rapid Assessment)

១. ចំនួន និស្សិត ដែលត្រូវមករៀននៅបរិវេណសាលា និងចំនួន និស្សិតសរុប

២. បទពិសោធន៍ដំណើរការកម្មវិធីសិក្សាចម្រុះ

៣. បទពិសោធន៍ដំណើរការកម្មវិធីការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក

**២. លក្ខខណ្ឌអប្បបរមាក្នុងការអនុវត្តកម្មវិធីការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក**

១. ដំណើរការផលិតមាតិកាឌីជីថល **(Digital Content)**

២. ការផ្សារភ្ជាប់មាតិកាឌីជីថលទៅលើប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិកត្រូនិក **(LMS)**

៣. ការផ្តល់មាតិកាឌីជីថលទៅកាន់អ្នកសិក្សា **(Synchronized, Asynchronized)**

៤. ភាពជាម្ចាស់នៃគ្រឹះស្ថានសិក្សា លើមាតិកាឌីជីថល និងប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិកត្រូនិក

៥. ប្រព័ន្ធ **Hosting, Data Center, Server** និងបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងដំណើរការ

**៣. ការរៀបចំបង្កើតក្រុមគ្រូបង្គោល សម្រាប់ការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក នៅតាមគ្រឹះស្ថានសិក្សា**

១. ក្រុមការងារផ្នែកប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិកត្រូនិក **(LMS)**

២. ក្រុមការងារផ្នែកគ្រប់គ្រងការប្រើប្រាស់វេទិកាឌីជីថល និងការផលិតមាតិកាឌីជីថល

**៤. ការរៀបចំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្នែកទន់**

១. ការប្រើប្រាស់ប្រព័ន្ធ **Software** សម្រាប់ដំណើរការប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិកត្រូនិក

២. ការប្រើប្រាស់ប្រព័ន្ធ **Software** ជាមធ្យោបាយ សម្រាប់ដំណើរការរៀន និងបង្រៀន

៣. ការទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ លើការរក្សាកិត្តិយសនិងសេចក្តីថ្លៃថ្នូរក្នុងការផលិត ចែកចាយ បង្ហោះ ឬការប្រើប្រាស់មាតិកាឌីជីថល

៤. ការរក្សាសុវត្ថិភាព និងការសម្ងាត់នៃទិន្នន័យនិងព័ត៌មានទាក់ទងនឹងការរៀននិងបង្រៀន

## ៥. ការរៀបចំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្នែករឹង

១. សម្ភារៈ និងមធ្យោបាយសម្រាប់ដំណើរការកម្មវិធីអប់រំតាមប្រព័ន្ធអេឡិកត្រូនិក តាមថ្នាក់រៀន

២. ការបំពាក់ទូរទស្សន៍វៃឆ្លាត

៣. ត្រូវរៀបចំបន្ទប់កុំព្យូទ័រ ដែលនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលនិស្សិតអាចមក **Download** មាតិកាឌីជីថល ដោយរក្សាគម្លាតសុវត្ថិភាព

៤. សម្ភារៈ និងមធ្យោបាយសម្រាប់គ្រប់គ្រងទិន្នន័យ ប្រព័ន្ធ **Hosting, Data Center, Server**

## ៦. ការរៀបចំ និងការកែលម្អកម្មវិធីសិក្សា

១. ការរៀននិងការបង្រៀន នឹងត្រូវធ្វើដោយប្រព័ន្ធទ្វេ **(Dual System)** គឺការជួបគ្នារវាងគ្រូ និងសិស្ស-និស្សិត **(Face to Face)** ក្នុងទ្រង់ទ្រាយតូចបំផុត ដើម្បីសាកសួរ សំណួរឬប្រគល់កិច្ចការ និងការអប់រំពីចម្ងាយ **(Distance Learning)** ដែលគ្រូ និងសិស្ស-និស្សិត ផ្តល់និងទទួលការអប់រំ (ការរៀននិងការបង្រៀន) ដោយពុំចាំបាច់មានវត្តមាននៅសាលារៀន ឬជួបគ្នាដោយផ្ទាល់។

២. ការវាយតម្លៃលទ្ធផលនៃការសិក្សា និងការប្រឡងបញ្ចប់ការសិក្សា តាមប្រព័ន្ធអេឡិកត្រូនិក ចំពោះនិស្សិតដែលពុំអាចមកកាន់បរិវេណសាលា។

## ឧបសម្ព័ន្ធទី៣

## គំរូមាគគានៃពិធីសារនៃ
## ការរៀបចំកាលវិភាគសិក្សា

ឧទាហរណ៍ ៖ សាលា "ក" មានថ្នាក់ឆ្នាំទី១ចំនួន៣ថ្នាក់។ គណៈគ្រប់គ្រង អាចសម្រេចបំបែកថ្នាក់ឆ្នាំទី១ "ក" ដែលមានសិស្សចំនួន៤០នាក់ ហើយមករៀនចំនួន៣០នាក់ ជា៣ជំរើស គឺបំបែកជា២វេន (១៥នាក់មករៀនពេលព្រឹក និង១៥នាក់ទៀតមកពេលរៀនពេលរសៀល) ឬបំបែកជា២បន្ទប់ (១៥នាក់រៀននៅបន្ទប់ទី១ និង១៥នាក់ទៀតរៀននៅបន្ទប់ទី២) ឬបំបែកជាថ្ងៃរៀន (១៥នាក់មករៀនថ្ងៃច័ន្ទនិងអង្គារ ១៥នាក់មករៀនថ្ងៃសុក្រនិងសៅរ៍ ដោយទុកថ្ងៃព្រហស្បតិ៍ និងអាទិត្យ សម្រាប់ការសម្អាតបរិវេណសាលារៀន)។

| ថ្នាក់ | ថ្នាក់រៀន | សិស្សសរុប | មករៀន | ការបំបែកវេន | ការបំបែកថ្នាក់ | ការបំបែកថ្ងៃ | ម៉ោងចូល | ម៉ោងសម្រាក | ម៉ោងចេញ |
|---|---|---|---|---|---|---|---|---|---|
| ១ | ក | ៤០ | ៣០ | ព្រឹក ១៥ | គ្មានបំបែក | ច័ន្ទ អង្គារ | ០៧៖០០ | ០៩៖០០ | ១១៖០០ |
| | | | | រសៀល ១៥ | | ច័ន្ទ អង្គារ | ១៣៖០០ | ១៥៖០០ | ១៧៖០០ |
| ១ | ខ | ៣០ | ២៥ | ពេញមួយថ្ងៃ | បន្ទប់A ១០ | សុក្រ សៅរ៍ | ០៧៖០០ | ០៩៖០០ | ១១៖០០ |
| | | | | | បន្ទប់B ១៥ | សុក្រ សៅរ៍ | ១៣៖០០ | ១៥៖០០ | ១៧៖០០ |
| ១ | គ | ២០ | ១៥ | ពេញមួយថ្ងៃ | គ្មានបំបែក | មិនលើស២ថ្ងៃ | ០៧៖០០ | ១២៖០០ | ១៧៖០០ |
| ២ | ក | ៣៥ | ២៨ | ព្រឹក ១៤ | គ្មានបំបែក | ច័ន្ទ អង្គារ | ០៧៖១៥ | ០៩៖១៥ | ១១៖១៥ |
| | | | | រសៀល ១៤ | | ច័ន្ទ អង្គារ | ១៣៖១៥ | ១៥៖១៥ | ១៧៖១៥ |
| ២ | ខ | ៣០ | ២២ | ពេញមួយថ្ងៃ | បន្ទប់A ១០ | សុក្រ សៅរ៍ | ០៧៖១៥ | ០៩៖១៥ | ១១៖១៥ |
| | | | | | បន្ទប់B ១២ | សុក្រ សៅរ៍ | ១៣៖១៥ | ១៥៖១៥ | ១៧៖១៥ |
| ២ | គ | ១៥ | ១២ | ពេញមួយថ្ងៃ | គ្មានបំបែក | មិនលើស២ថ្ងៃ | ០៧៖១៥ | ១២៖១៥ | ១៧៖១៥ |

# ឧបសម្ព័ន្ធទី៤

## គំរូមាគគាំនៃពិធីសារនៃ
## ការរៀបចំបន្ទប់រៀន

ឧទាហរណ៍ ៖ សាលា "ក" មានបន្ទប់រៀនចំនួន១០បន្ទប់ ដែលក្នុងនោះគឺបន្ទប់ខ្នាតតូចសម្រាប់សិស្សរៀនចំនួន៦បន្ទប់ (ថ្នាក់ឆ្នាំទី១មាន៣បន្ទប់ និងថ្នាក់ឆ្នាំទី២មាន៣បន្ទប់) បន្ទប់ខ្នាតធំសម្រាប់ការជួបជុំ១បន្ទប់ បណ្ណាល័យ១បន្ទប់ ថ្នាក់រៀនកុំព្យូទ័រ១បន្ទប់ និងមន្ទីរពិសោធន៍១បន្ទប់។

| បន្ទប់ | ប្រើប្រាស់ | ទំហំ (ទទឹង និង បណ្ដោយ) | ចំនួនមនុស្ស ក្នុងមួយពេល | គម្លាត សុវត្ថិភាព | ចំនួន កន្លែងលាងដៃ | ចំនួនទីតាំង ដែលអាល់កុល ដាក់ក្នុងបន្ទប់ | សីតុណ្ហភាព | ទំហំបង្អួច | ចំនួនច្រកទ្វារ |
|---|---|---|---|---|---|---|---|---|---|
| ១ | ថ្នាក់ឆ្នាំទី១ -ក- | | | | | | | | |
| ២ | ថ្នាក់ឆ្នាំទី១ -ខ- | | | | | | | | |
| ៣ | ថ្នាក់ឆ្នាំទី១ -គ- | | | | | | | | |
| ៤ | ថ្នាក់ឆ្នាំទី២ -ក- | | | | | | | | |
| ៥ | ថ្នាក់ឆ្នាំទី២ -ខ- | | | | | | | | |
| ៦ | ថ្នាក់ឆ្នាំទី២ -គ- | | | | | | | | |
| ៧ | បន្ទប់ប្រជុំ | | | | | | | | |
| ៨ | បណ្ណាល័យ | | | | | | | | |
| ៩ | កុំព្យូទ័រ | | | | | | | | |
| ១០ | បន្ទប់ពិសោធន៍ | | | | | | | | |

## ឧបសម្ព័ន្ធទី៥

## លិខិតធានាអះអាងលើកច្បព្រមព្រៀងរវាងគ្រឹះស្ថានសិក្សា ជាមួយអ្នកសិក្សា និងអ្នកអាណាព្យាបាល បុគ្គលិកអប់រំ និងបុគ្គលពាក់ព័ន្ធទាំងអស់ ស្តីពីសោហ៊ុយចំណាយសម្រាប់ការធ្វើតេស្ត និងសោហ៊ុយចំណាយសម្រាប់ការព្យាបាលអ្នកជំងឺ

ខ្លឹមសារលិខិត (ឧបសម្ព័ន្ធទី៦) ជាការគោរពជូនក្រសួងអប់រំ យុវជន និងកីឡា នូវព័ត៌មាន និងការធានាអះអាងដូចខាងក្រោម ៖

១. គ្រឹះស្ថានសិក្សា ត្រូវរាយការណ៍ប្រកបដោយការទទួលខុសត្រូវបំផុត នូវចំនួន និស្សិត បុគ្គលិកអប់រំ និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត ដែលទើបមកដល់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅ១ខែចុងក្រោយ មុនដំណើរការបើកគ្រឹះស្ថានសិក្សា។

២. ក្នុងករណីចាំបាច់ គ្រឹះស្ថានសិក្សា ឯកភាពជាមួយលក្ខខណ្ឌតម្រូវនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ក្នុងការអនុវត្តការធ្វើតេស្តពិនិត្យវត្តមានមេរោគនៃជំងឺកូវីដ-១៩ លើបុគ្គលដែលសង្ស័យ និងដែលអាចមានហានិភ័យ

៣. គ្រឹះស្ថានសិក្សានិងបុគ្គលដែលត្រូវធ្វើតេស្តពិនិត្យវត្តមានមេរោគនៃជំងឺកូវីដ-១៩ (ក្នុងករណីចាំបាច់) បានព្រមព្រៀងគ្នារួចហើយ លើការទូទាត់ការចំណាយថវិកាសម្រាប់ការធ្វើតេស្ត

៨.៤ គ្រឹះស្ថានសិក្សា នឹងអនុញ្ញាតជូនអ្នកសិក្សា និងបុគ្គលិកអប់រំ ដែលត្រូវមានវត្តមានក្នុងសាលារៀន ហើយដែលមានលទ្ធផលអវិជ្ជមានលើតេស្តពិនិត្យវត្តមានមេរោគនៃជំងឺកូវីដ-១៩ និងដែលពុំមានហានិភ័យ វិលត្រឡប់មកកាន់បរិវេណសាលារៀន

# ឧបសម្ព័ន្ធទី៦

# តារាងស្វ័យវាយតម្លៃនៃគ្រឹះស្ថានសិក្សា

| ល.រ | **សូចនាករនៃការអនុវត្ត** | ✓ (រួច) ឬ × (ពុំទាន់ធ្វើ) |
|---|---|---|
| **គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទ នៃជំងឺកូវីដ-១៩** | | |
| **១** | **អភិបាលកិច្ចក្របខណ្ឌច្បាប់ និងយន្តការ** | |
| ក | បង្កើត និងពង្រឹងភារកិច្ចរបស់ **គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា** ដោយកំណត់សមាសភាព និងភារកិច្ចច្បាស់លាស់ | |
| ខ | ដាក់បញ្ចូលនិងពង្រឹងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពសិក្សា ដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន និងការ រៀបចំដំណើរការបន្ទប់សុខភាព | |
| គ | ការផ្សព្វផ្សាយសេចក្តីណែនាំនានារាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការលើកកម្ពស់សុខភាព ការបង្ការជំងឺ ឬការបង្ការគ្រោះថ្នាក់ ដែលបានដាក់ចេញនាពេលកន្លងមក | |
| **២.** | **ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសិក្សា** | |
| **២.១.** | **ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ជាសុភភាព និងមេត្រីភាព** | |
| ក | ការរក្សាសីតុណ្ហភាពក្នុងបន្ទប់រៀនមិនទាបជាង ២៤ អង្សាសេ | |
| ខ | ការអនុវត្តវិធានរម្ងាប់មេរោគ មុននឹងដាក់ឱ្យដំណើរការគ្រឹះស្ថានសិក្សា (បន្ទប់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ កន្លែងសម្អាតដៃ សួនកម្សាន្ត និងសម្ភារប្រើប្រាស់) | |
| គ | ការរៀបចំធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារ និងបរិវេណគ្រឹះស្ថានសិក្សា និងត្រូវគ្រប់គ្រងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ | |
| ឃ | ការសម្អាត ឬរម្ងាប់មេរោគឱ្យបានញឹកញាប់នៅតាមកន្លែង ឬផ្ទៃលើនៃវត្ថុ ដែលអាចមានមនុស្សច្រើនប៉ះពាល់ដូចជា ដៃទ្វារ តុ កៅអី | |
| ង | ការបើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា | |
| ច | ការពាក់ម៉ាស់ ពាក់ស្រោមដៃ និងស្បែកជើងឱ្យបានត្រឹមត្រូវមុនពេល និងក្នុងពេលសម្អាត ចំពោះអ្នកទទួលខុសត្រូវការសម្អាត | |
| **២.២.** | **ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាគម្លាតសុវត្ថិភាពក្នុងគ្រឹះស្ថានសិក្សា** | |
| ក្ក | ការរៀបចំតុ កៅអីអង្គុយសម្រាប់សិស្សានុសិស្សនៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច១,៥ម៉ែត្រ | |
| ខ្ខ | ការបើកច្រកទ្វារចេញចូលក្នុងបរិវេណគ្រឹះស្ថានសិក្សាទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្ស ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី២ម៉ែត្រឡើងទៅ នៅច្រកទ្វារចូលគ្រឹះស្ថានសិក្សា | |
| គ្គ | ការរៀបចំការគោរពទង់ជាតិក្នុងទ្រង់ទ្រាយតូចជាតំណាង ដើម្បីជានាគម្លាតសុវត្ថិភាព ដោយធ្វើការផ្លាស់វេនតាមថ្នាក់ | |
| ឃ្ឃ | ការបែងចែកវេនសិស្សមួយចំនួននៅក្នុងបន្ទប់ និងមួយចំនួនចេញក្រៅបន្ទប់រៀន នៅពេលចេញលេងម្តងៗ ព្រមទាំងត្រូវធានាគម្លាតសុវត្ថិភាពពេលចូលប្រើប្រាស់បង្គន់អនាម័យ ឬកន្លែងលាងសម្អាតដៃ | |

| | | |
|---|---|---|
| ង្ | ការរៀបចំកាលវិភាគចេញពីគ្រឹះស្ថានសិក្សាម្ដងមួយថ្នាក់ៗតាមលំដាប់លំដោយ នៅពេលចប់ម៉ោងសិក្សាចេញទៅផ្ទះ | |
| ច្ | ការផ្អាកដំណើរការបណ្ណាល័យ និងមិនត្រូវឱ្យមានការខ្ចីសៀវភៅគ្នាទៅវិញទៅមក | |
| ឆ្ | ការបិទទ្វាររបងគ្រឹះស្ថានសិក្សា ព្រមទាំងចាត់តាំងការយាមកាមឱ្យបានហ្មត់ចត់ អំឡុងពេលម៉ោងសិក្សា ដោយមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញចូលឡើយ | |
| ជ្ | ការចៀសវាងការប្រមូលផ្ដុំគ្រប់រូបភាព ទាំងអំឡុងពេលម៉ោងសិក្សា ឬក្រៅម៉ោងសិក្សា | |
| ឈ្ | ការរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច២ម៉ែត្រឡើងទៅ នៅក្នុងការប្រាស្រ័យទាក់ទងនានា ក្នុងបរិវេណគ្រឹះស្ថានសិក្សា | |
| ញ | ការផ្អាកកន្លែងកំសាន្ត ឬទីលានកីឡា ដែលមានលក្ខណៈប្រមូលផ្ដុំក្នុងបរិវេណគ្រឹះស្ថានសិក្សាជាបណ្ដោះអាសន្ន | |
| ដ្ | ការហាមឃាត់ការរៀបចំព្រឹត្តិការណ៍សហគមន៍ ឬការជួបជុំណាមួយនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ដើម្បីចៀសវាងហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ | |
| ២.៣. | **ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត** | |
| ក | ការអប់រំ ផ្សព្វផ្សាយ បង្កើតទម្លាប់រស់នៅធម្មតាតាមគន្លងថ្មី ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការសុវត្ថិភាពសុខភាព | |
| ខ | ការរៀបចំបន្ទប់សុខភាព និងចាត់តាំងឱ្យមានគ្រូទទួលបន្ទុកសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ សម្រាប់ការសង្គ្រោះបឋម និងការពិនិត្យសុខភាព | |
| គ | ការណែនាំឱ្យអ្នកសិក្សា និងបុគ្គលិកអប់រំ បំពេញព័ត៌មានសុខភាព និងប្រវត្តិធ្វើដំណើរមកពីក្រៅប្រទេស ដើម្បីពិនិត្យតាមដាននិងរក្សាទុកឯកសារ | |
| ឃ | ការណែនាំមាតាបិតា អ្នកអាណាព្យាបាល ផ្ដល់ព័ត៌មានអំពីសុខភាព និងប្រវត្តិនៃការធ្វើដំណើរក្នុង និងក្រៅប្រទេស និងការជួបជុំដែលអាចបង្កើតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ | |
| ង | ការចាត់វិធានការវាស់កម្ដៅអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សាជាប្រចាំមុនពេលចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា | |
| ច | ការអនុញ្ញាតបានឈប់សម្រាកចំពោះបុគ្គលដែលមានអាការៈសង្ស័យណាមួយ ឬអ្នកដែលមានប្រវត្តិធ្វើដំណើរមកពីក្រៅប្រទេស ឬអ្នកធ្លាប់ប៉ះពាល់អ្នកជំងឺកូវីដ-១៩ ដែលមិនទាន់បានធ្វើចត្តាឡីស័ក១៤ថ្ងៃ | |
| ឆ | ការរៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចូលសាលា និងពេលចេញពីសាលា ដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់ និងពេលចេញ | |
| ២.៤. | **ការផ្ដល់អាហារូបត្ថម្ភ និងអាហារប្រកបដោយសុវត្ថិភាព** | |
| ក | ការណែនាំ និងផ្សព្វផ្សាយដល់មាតាបិតា ឬអ្នកអាណាព្យាបាល ឱ្យយកចិត្តទុកដាក់រៀបចំចំណីអាហារប្រកបដោយសុវត្ថិភាព និងសុខភាពត្រឹមត្រូវ ដល់បុត្រ-បុត្រធីតា | |
| ខ | ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត ទាំងអស់គួរយកចំណីអាហារពីផ្ទះរៀងៗខ្លួន ដើម្បីយកមកទទួលទាននៅតាមគ្រឹះស្ថានសិក្សា | |
| គ | ការរៀបចំសណ្ដាប់ធ្នាប់កន្លែងទទួលទានចំណីអាហារប្រកបដោយអនាម័យជាប់ជាប្រចាំ និងកំណត់ឱ្យអ្នកទទួលទានទាំងអស់ស្ថិតនៅឃ្លាតពីគ្នាចាប់ពី ១,៥ម៉ែត្រឡើងទៅ | |
| ឃ | ការហាមឃាត់ការលក់ចំណីអាហារនៅក្នុង និងក្រៅជាប់របងគ្រឹះស្ថានសិក្សា | |

| | | |
|---|---|---|
| **២.៥** | **ការផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខារអនាម័យ** | |
| ក | ការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងគ្រឹះស្ថានសិក្សា ជូនដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត លើកទឹកចិត្តឱ្យនាំយកទឹកស្អាតពីផ្ទះ សម្រាប់ទុកទទួលទានផ្ទាល់ខ្លួន | |
| ខ | ការរៀបចំបរិក្ខារលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ ឬក្បែរបន្ទប់រៀន ដោយមានសាប៊ូ និងមានទឹកស្អាតប្រើប្រាស់ជាប្រចាំ | |
| គ | ការរៀបចំបរិក្ខារលាងសម្អាតដៃជាបណ្តោះអាសន្ន ចំពោះគ្រឹះស្ថានសិក្សាដែលមិនទាន់មានបរិក្ខារលាងសម្អាតដៃ និងដាក់វេនសម្អាតឱ្យបានត្រឹមត្រូវជាប្រចាំថ្ងៃ | |
| ឃ | ការផ្គត់ផ្គង់ទឹករម្ងាប់មេរោគដូចជា ទឹកអាល់កុល ឬទឹកដែលលាងសម្អាតដៃ សម្រាប់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សាបានប្រើប្រាស់ប្រចាំថ្ងៃ | |
| ង | ការថែទាំបង្គន់អនាម័យឱ្យស្អាតជាប្រចាំ ដោយមានទឹក សាប៊ូ និងត្រូវបើកឱ្យប្រើប្រាស់រៀងរាល់ម៉ោងសិក្សា ព្រមទាំងបែងចែកបង្គន់សម្រាប់ប្រុស និងបង្គន់សម្រាប់ស្រីដាច់ពីគ្នា ហើយត្រូវដាក់វេនសម្អាត | |
| **២.៦** | **ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ-១៩** | |
| ក | ការបិទផ្សាយរូបភាពផ្ទាំងធំ និងខិតបណ្ណអប់រំសុខភាពនានា ជាពិសេសរបៀបលាងសម្អាតដៃ វិធីការពារ បង្ការជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថានសិក្សា | |
| ខ | ការរៀបចំ និងពង្រឹងការអប់រំផ្សព្វផ្សាយខ្លឹមសារសុខភាពសំខាន់ៗពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ឬជំងឺឆ្លងស្រួចស្រាល់នានាដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀត | |
| គ | ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ស្តីពីសារៈសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថានសិក្សា | |
| ឃ | ការប្រើប្រាស់ និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់ និងផ្លូវការ ស្តីពីស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ១៩ ដូចជាក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ឬក្រសួង | |
| ង | ការណែនាំអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ឱ្យគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ ដោយមិនត្រូវស្ថិតក្រោមទស្សនៈ -ការភ័យខ្លាច និងការរើសអើង- | |
| ច | ការតាមដានមូលហេតុអវត្តមានរបស់បុគ្គលិកអប់រំ អ្នកសិក្សា និងបុគ្គលិកបម្រើការផ្សេងទៀត ក្នុងករណីសង្ស័យមានជំងឺផ្លូវដង្ហើម ឬជំងឺឆ្លងនានា ត្រូវជូនដំណឹងទៅមន្ត្រីសុខាភិបាល និងអ្នកពាក់ព័ន្ធ | |
| ឆ | ការហាមឃាត់អ្នកសិក្សា បុគ្គលិកអប់រំ និង បុគ្គលិកបម្រើការផ្សេងទៀតមិនឱ្យធ្វើដំណើរទៅកន្លែងមានអត្រាឆ្លងជំងឺកូវីដ-១៩ និងមិនត្រូវរៀបចំសកម្មភាពណាដែលបង្កឱ្យមានហានិភ័យនៃការចម្លងរោគ | |
| ជ | ការអនុវត្តវិធានការអនាម័យជាប់ជាប្រចាំ ដោយការលាងសម្អាតដៃឱ្យបានញឹកញាប់ជាមួយទឹកនិងសាប៊ូ យ៉ាងតិច៤០វិនាទី ក្នុងពេលលាងសម្អាតម្តង | |
| ឈ | ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការឱ្យយកជាប់តាមខ្លួននូវទឹកអាល់កុល ឬទឹកដែលលាងដៃ និងពាក់ម៉ាសការពារ | |
| ញ | ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការក្នុងការអនុវត្តការញើសសំបោរ ការខាកស្តោះឱ្យត្រឹមត្រូវនៅបន្ទប់ទឹក ឬបង្គន់អនាម័យ | |
| ដ | ការណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ ឬបុគ្គលិកបម្រើការផ្សេងទៀតធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្តាស់ដោយប្រើគន្លាក់កែងដៃ ឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាម | |
| ឋ | ការហាមឃាត់អ្នកសិក្សា បុគ្គលិកអប់រំ និង បុគ្គលិកបម្រើការផ្សេងទៀត ប៉ះពាល់គ្នាដោយផ្ទាល់ ដូចជាការចាប់ដៃ ឬប្រើប្រាស់របស់របររួមគ្នា និងត្រូវលើកកម្ពស់ការគោរពគ្នាដោយការសំពះ | |
| ឌ | ការណែនាំអោយចៀសវាងការប៉ះពាល់ជាមួយអ្នកជំងឺ (គ្រុនក្តៅ ក្អក ហៀរសំបោរ ផ្តាសាយ) ក្នុងករណីគ្មានសម្ភារការពារខ្លួន និងមិនត្រូវយកដៃប៉ះភ្នែក ច្រមុះ និងមាត់ឡើយ | |

| | | |
|---|---|---|
| ឈ | ការផ្អាកដំណើរការជាបណ្ដោះអាសន្ននូវការប្រើប្រាស់រថយន្តដឹកជញ្ជូនអ្នកសិក្សារួមគ្នា រហូតដល់មានការអនុញ្ញាតសាជាថ្មី | |
| ញ | ការត្រៀមយន្តការសម្រាប់ណែនាំអ្នកបើកបររថយន្តដឹកសិស្សឱ្យពាក់ម៉ាសពេលបើកបរ បង្កើបបង្អួចឱ្យខ្យល់ចេញចូល និងទុកចន្លោះទំនេរ១កៅអី (នៅពេលមានការអនុញ្ញាតអោយប្រើរថយន្តឡើងវិញ) | |
| ដ | ការត្រៀមយន្តការសម្រាប់ការពិនិត្យកម្ដៅអ្នកសិក្សា និងអ្នកបើកបរមុនអនុញ្ញាតឱ្យឡើងជិះរថយន្ត លាងសម្អាតដៃនឹងអាល់កុលឬជែលលាងដៃ (នៅពេលមានការអនុញ្ញាតអោយប្រើរថយន្តឡើងវិញ) | |
| ឋ | ការគាំទ្រផ្នែកសង្គមដល់ អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតដើម្បីឱ្យពួកគេចេះទប់ទល់នឹងជំងឺធ្លាក់ទឹកចិត្ត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ | |
| **៣.** | **ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ** | |
| **៣.១.** | **អាជ្ញាធរអប់រំ** | |
| ក | ការពង្រឹងកិច្ចសហការរវាងមន្ទីរអប់រំ ការិយាល័យអប់រំ គណៈគ្រប់គ្រង គណៈកម្មការទ្រទ្រង់គ្រឹះស្ថានសិក្សា ជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីការចូលរួមការបង្ការ ទប់ស្កាត់ជំងឺកូវីដ-១៩ | |
| **៣.២.** | **អាជ្ញាធរដែនដី** | |
| ក | ការសហការជាមួយអាជ្ញាធរដែនដីក្នុងការទទួលបានព័ត៌មានពីហានិភ័យដែលអាចកើតមានឡើងពីការចេញចូលនៃប្រជាជនចំណាកស្រុកនៅតាមមូលដ្ឋាន ឬព័ត៌មានពីការគ្រប់គ្រងអ្នកចំណូលថ្មី | |
| **៣.៣.** | **ភ្នាក់ងារសុខាភិបាល** | |
| ក | ការពង្រឹងកិច្ចសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីរៀបចំប្រព័ន្ធត្រួតពិនិត្យ និងអធិការកិច្ចជាប្រចាំនៅតាមគ្រឹះស្ថានសិក្សា និងធានាការអនុវត្តវិធានការសុវត្ថិភាពសុខភាពសិក្សា | |
| ខ | ការសហការជាមួយមន្ត្រីសុខាភិបាលក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីគាំទ្រនិងតាមដានសុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ | |
| គ | ការសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីរៀបចំប្រព័ន្ធត្រួតពិនិត្យ និងអធិការកិច្ចជាប្រចាំនៅតាមគ្រឹះស្ថានសិក្សា និងធានាការអនុវត្តវិធានការសុវត្ថិភាពសុខភាពសិក្សា | |
| **៤.** | **វិធីសាស្ត្រក្នុងការរាយការណ៍អំពីករណីផ្សេងៗ** | |
| **៤.១.** | **ករណីបុគ្គលិកអប់រំ គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្ដៅខ្ពស់** | |
| ក | ការរៀបចំយន្តការ និងនីតិវិធីក្នុងករណីមានការពិនិត្យឃើញថា បុគ្គលិកអប់រំ គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្ដៅលើសពី ៣៧,៥ អង្សាសេ | |
| **៤.២** | **ការធ្វើរបាយការណ៍ទៅក្រសួងសុខាភិបាល** | |
| ក | ការរៀបចំយន្តការ និងនីតិវិធី ដើម្បីអោយគណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ត្រូវជូនដំណឹងដល់មន្ទីរសុខាភិបាលជាបន្ទាន់ ក្នុងពេលមានការរកឃើញករណីសង្ស័យ | |
| **៤.៣.** | **ការរួមសហការឆ្លើយតបជំងឺកូវីដ-១៩** | |
| ក | ត្រូវផ្ដល់ឈ្មោះជនបង្គោល និងព័ត៌មានទំនាក់ទំនងជាមួយមន្ត្រីជំនាញសុខាភិបាល ដើម្បីងាយស្រួលទាក់ទងគ្នាចូលរួមអង្កេតស្រាវជ្រាវតាមវិធានការរបស់ក្រសួងសុខាភិបាល | |
| **៤.៤.** | **ការអនុវត្តវិធានការផ្លូវច្បាប់ ចំពោះការធ្វេសប្រហែស** | |
| ក | ការប្រកាសទទួលស្គាល់ថា អង្គភាពជំនាញនៅគ្រប់ជាន់ថ្នាក់ មានភារកិច្ចគ្រប់គ្រង និងតាមដានការអនុវត្តសេចក្ដីណែនាំនេះ និងការសុខចិត្តទទួលវិធានការច្បាប់ និងវិធានការរដ្ឋបាល។ | |
| **៤.៥** | **ការធ្វើរបាយការណ៍** | |
| ក | ការរៀបចំយន្តការ និងនីតិវិធីនៃការធ្វើរបាយការណ៍ប្រចាំខែ ស្ដីពីដំណើរការរបស់គ្រឹះស្ថានសិក្សា និងការអនុវត្តតាមអនុស្សរណៈយោគយល់គ្នា ឱ្យបានទៀងទាត់មកក្រសួងអប់រំ យុវជន និងកីឡា | |

| ល.រ | សូចនាករនៃការអនុវត្ត | ការបំពេញព័ត៌មាន |
|---|---|---|
| **ការអនុវត្តកម្មវិធីអប់រំពីចម្ងាយ និងការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក** | | |
| **១** | **ការវាយតម្លៃរហ័សលើស្ថានភាពជាក់ស្តែង (Rapid Assessment)** | |
| ក | តើគ្រឹះស្ថានសិក្សា បានបូកស្រង់ស្ថិតិចំនួន និស្សិត ដែលត្រូវមករៀននៅបរិវេណសាលា និងចំនួនសិស្ស និស្សិតសរុប ហើយឬនៅ? | |
| ខ | ចូរបង្ហាញដោយសង្ខេប ពីបទពិសោធន៍ដំណើរការកម្មវិធីសិក្សាចម្រុះ? | |
| គ | ចូរបង្ហាញដោយសង្ខេប ពីបទពិសោធន៍ដំណើរការកម្មវិធីការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក? | |
| **២** | **លក្ខខណ្ឌអប្បបរមាក្នុងការអនុវត្តកម្មវិធីការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក** | |
| ក | តើអ្នកណាជាអ្នកផលិតមាតិកាឌីជីថល (Digital Content)? តើមាតិកាឌីជីថលត្រូវបានផលិតសម្រាប់គ្រប់មុខវិជ្ជា ឬវគ្គសិក្សាឬនៅ? | |
| ខ | តើគ្រឹះស្ថានសិក្សា បានផ្សារភ្ជាប់មាតិកាឌីជីថលទៅលើប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក (Learning Management System) ឬទេ? | |
| គ | តើមាតិកាឌីជីថលទៅកាន់អ្នកសិក្សា ជាលក្ខណៈSynchronous ឬ Asynchronous? | |
| ឃ | តើគ្រឹះស្ថានសិក្សា មានភាពជាម្ចាស់នៃគ្រឹះស្ថានសិក្សា លើមាតិកាឌីជីថល និងប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក ឬទេ? | |
| ង | តើគ្រឹះស្ថានសិក្សា មានបំពាក់ប្រព័ន្ធ Hosting, Data Center, Server ហើយឬនៅ? | |
| **៣** | **ក្រុមគ្រូបង្គោល សម្រាប់ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក នៅតាមគ្រឹះស្ថានសិក្សា** | |
| ក | តើគ្រឹះស្ថានសិក្សា មានក្រុមការងារផ្នែកប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក (LMS) ប៉ុន្មានរូប? | |
| ខ | តើគ្រឹះស្ថានសិក្សា មានក្រុមការងារផ្នែកគ្រប់គ្រង និងត្រួតពិនិត្យ ការប្រើប្រាស់វេទិកាឌីជីថល និងខ្លឹមសារនៃការផលិតមាតិកាឌីជីថលឬទេ? | |
| **៤** | **ការរៀបចំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្នែកទន់** | |
| ក | ចូរបរិយាយពីប្រព័ន្ធ Software សម្រាប់ដំណើរការប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក | |
| ខ | ចូរបរិយាយពីប្រព័ន្ធ Software ជាមធ្យោបាយ សម្រាប់ដំណើរការរៀន និងបង្រៀន | |
| គ | ចូរបរិយាយពីការរក្សាកិត្តិយសនិងសេចក្តីថ្លៃថ្នូរក្នុងការផលិត ចែកចាយ បង្ហោះ ឬការប្រើប្រាស់មាតិកាឌីជីថល | |
| ឃ | ចូរបរិយាយពីការរក្សាសុវត្ថិភាព និងការសម្ងាត់នៃទិន្នន័យនិងព័ត៌មានទាក់ទងនឹងការរៀននិងបង្រៀន | |
| **៥** | **ការរៀបចំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្នែករឹង** | |
| ក | តើគ្រឹះស្ថានសិក្សា មានបំពាក់សម្ភារៈ និងមធ្យោបាយសម្រាប់ដំណើរការកម្មវិធីអប់រំតាមប្រព័ន្ធអេឡិចត្រូនិក តាមថ្នាក់រៀនគ្រប់គ្រាន់ឬនៅ? | |
| ខ | តើគ្រឹះស្ថានសិក្សា មានបំពាក់ទូរទស្សន៍វៃឆ្លាត ឬ Smart Board សម្រាប់ប្រើប្រាស់ក្នុងថ្នាក់រៀនឬទេ? | |

| | | |
|---|---|---|
| គ | តើគ្រឹះស្ថានសិក្សាបានរៀបចំបន្ទប់កុំព្យូទ័រដែលនិស្សិតអាច **Download** មាតិកានីជីថល ដោយរក្សាគម្លាតសុវត្ថិភាពឬទេ? | |
| ឃ | ចូរបកស្រាយពីសម្ភារៈ និងមធ្យោបាយសម្រាប់គ្រប់គ្រងទិន្នន័យ ប្រព័ន្ធ **Hosting, Data Center, Server** | |
| **៦** | **ការរៀបចំ និងការកែលម្អកម្មវិធីសិក្សា** | |
| ក | តើគ្រឹះស្ថានសិក្សា បានកែលំអកម្មវិធីសិក្សា ជាលក្ខណៈការអប់រំពីចម្ងាយ ឬទេ? | |
| ខ | តើគ្រឹះស្ថានសិក្សា មានប្រព័ន្ធវាយតម្លៃលទ្ធផលនៃការសិក្សា និងការប្រឡងបញ្ចប់ការសិក្សា តាមប្រព័ន្ធអេឡិកត្រូនិក ឬទេ? | |

ខ្ញុំបាទ/ នាងខ្ញុំ សូមធ្វើការអះអាងថា ព័ត៌មាន និងការបំពេញលក្ខខណ្ឌ នៃការរៀបចំដែលបានកំណត់ខាងលើ សុទ្ធសឹងតែជាការពិតប្រាកដ។

ប្រសិនបើព័ត៌មាន និងការបំពេញលក្ខខណ្ឌដែលមានកំណត់ខាងលើមានភាពមិនពិតប្រាកដ ឬមិនអាចអនុវត្តបានបានគ្រប់ជ្រុងជ្រោយ នោះក្រសួងមានសិទ្ធ នឹងអនុវត្តវិធានការគតិយុត្ត ដែលកំពុងមានជាធរមាន។